# ជំពូក ៧

## ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការណ៍កាត់បន្ថយ

## Environmental Impacts and Mitigation Measures

Draft

# ជំពូកទី ៧

## ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការណ៍កាត់បន្ថយ

### ៧.១ សេចក្តីផ្តើម (Indroduction)

ការសិក្សានេះយោងតាមអនុក្រឹត្យស្តីអំពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ចូលជាធរមាននៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ។ គំរោងវិនិយោគសាងសង់វារីអគ្គិសនីកំចាយរបស់ ក្រុមហ៊ុន Kamchay Sinohydro Hydroelectric Co,Ltd. បានចុះធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំរបាយការណ៍ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA) ចាប់ពីថ្ងៃទី ១៥ ខែ កុម្ភៈ ដល់ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ។

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គម (ESIA) នេះគឺជាការអង្កេត សិក្សាស្រាវជ្រាវ ដើម្បីរក និងកំណត់ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance)- ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ហេតុប៉ះពាល់បរិស្ថានទាំងនោះ ត្រូវរកវិធានការណ៍កាត់បន្ថយឱ្យដល់កំរិតអតិបរមា និងធ្វើផែនការគ្រប់គ្រងបរិស្ថាននៃដំណាក់កាលរបស់គំរោងទាំងនោះ ដោយមានការអនុវត្តពីម្ចាស់គំរោង រួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័នជំនាញ ពាក់ព័ន្ធ ដូចជា មន្ទីរបរិស្ថានខេត្ត, មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត, មន្ទីរធនធានទឹក និងឧតុនិយម, មន្ទីរកសិកម្មខេត្ត, មន្ទីររៀបចំដែនដីនគររូបនីយកម្ម និងសំណង់ខេត្ត, អាជ្ញាធរមូលដ្ឋាន គ្រប់លំដាប់ថ្នាក់, ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយពីក្រសួងបរិស្ថាន, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់ ។ ក្នុងដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះ ក្រុមការងារ SAWAC បានប្រើប្រាស់ក្រដាស់ Checklist ដើម្បីកំណត់ទំហំនៃការប៉ះពាល់ រួចជ្រើសយកការវាយតំលៃ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណាដែលមានកំរិត តិច មធ្យម និងខ្លាំង មកធ្វើវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ទាំងនេះឱ្យដល់កំរិតអប្បបរមា ។

### ៧.២ វិធីសាស្ត្រ (Methodology)

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA) នេះគឺជាការអង្កេត សិក្សាស្រាវជ្រាវ និងការប្រជុំពិភាក្សាជាមួយសហគមន៍/ប្រជាជនមូលដ្ឋាន អង្គការនានា និងស្ថាប័នជាប់ទាក់ទងនឹងគំរោងគ្រប់ជាន់ថ្នាក់ លើទីតាំងគំរោង សមាសភាពគំរោង ការងារសាងសង់គំរោង និងកិច្ចដំណើរការរបស់វា ដើម្បីស្វែងរក និងកំណត់ ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ហេតុប៉ះពាល់បរិស្ថានទាំងនោះ ត្រូវរកវិធានការណ៍កាត់បន្ថយ និងធ្វើផែនការគ្រប់គ្រងបរិស្ថាន នៃដំណាក់កាលរបស់គំរោងទាំងនោះ ដោយមានការអនុវត្តន៍ពីម្ចាស់គំរោង រួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័ន ជំនាញពាក់ព័ន្ធ ដូចជា មន្ទីរបរិស្ថានខេត្តកំពត , មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត , មន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តកំពត , ឧទ្យានជាតិ បូកគោ , មន្ទីរទេសចរណ៍ខេត្តកំពត , ខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពត , អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ , ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយពីក្រសួងបរិស្ថាន

, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល , ក្រសួងធនធានទឹក និងឧតុនិយម , ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួងទេសចរណ៍។ ក្នុងដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង សង្គម នេះ ក្រុមការងារ SAWAC បានប្រើប្រាស់តារាង Checklist សំរាប់គំរោងវារីអគ្គិសនី (គោលការណ៍ណែនាំ វ.ហ.ប របស់ធនាគារអភិវឌ្ឍអាស៊ី) ដើម្បីកំណត់ទំហំនៃការប៉ះពាល់ រួចជ្រើសយកការវាយតំលៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណា ដែលមានកំរិត មធ្យម និងខ្លាំង មកធ្វើវិធាន ការណ៍កាត់បន្ថយហេតុប៉ះពាល់ទាំងនេះឱ្យដល់កំរិតអប្បបរមា ។

<u>តារាង Checklist សំរាប់គំរោងវារីអគ្គិសនី :</u>

| **ក. ទីតាំងគំរោង:**<br>*តើតំបន់គំរោងនៅក្នុងឬក្បែរតំបន់បរិស្ថានសំខាន់ៗដែរទេ ?* | **មាន** | **គ្មាន** | **កត់សំគាល់** |
|---|---|---|---|
| • ទីតាំងមរតកវប្បធមិ | | ✓ | |
| • តំបន់ការពារ | ✓ | | [redacted] |
| • តំបន់ដីសើម | | ✓ | |
| • កោងកាង | | ✓ | មិនមានកោងកាងទេនៅក្បែរទំនប់តែមានខ្លះនៅតាមដងព្រែកក្បែរទីរួមខេត្តកំពត(ប្រហែល១០ គ.ម.) |
| • មាត់ពាម (តំបន់ទឹកភ្លាវ) | ✓ | | ព្រែកកំពុងបាយ |
| • តំបន់ទ្រនាប់នៃតំបន់ការពារ | ✓ | | [redacted] |
| • តំបន់ពិសេសសំរាប់ការពារជីវចំរុះ | ✓ | | [redacted] |
| **ខ. ផលប៉ះពាល់បរិស្ថានសំខាន់ៗ**<br>*តើគំរោងនឹងបង្កឱ្យ......* | | | |
| • បាត់បង់សម្បត្តិអេកូឡូស៊ីដ៏មានតំលៃ ដោយសារការលិចលង់ តំបន់កសិកម្ម/ព្រៃឈើ , ជំរកសត្វព្រៃ , រំខានដល់ត្រីពង /បង្កកំនើត និងឧបសគ្គដល់ផ្លូវ បំលាស់ទីរបស់ត្រី ដែរទេ? | ✓ | | [redacted] |
| • បាត់បង់វត្ថុបុរាណ , រូបសំណាកប្រវត្តិសាស្ត្រ រូបសំណាកវប្បធមិ ដែរទេ? | | ✓ | |
| • ការផ្លាស់ទី ឬ ការតាំងលំនៅឡើងវិញ របស់ប្រជាជនដោយអចេតនា ដែរទេ? | ✓ | | [redacted] |
| • ការរំខាន/ឧបសគ្គ ដល់ក្រុមកុលសម្ព័ន្ធ / ប្រជាជនអន្តោប្រាម ដែរទេ? | | ✓ | |
| • ការថយចុះបរិស្ថានចេញពីកំនើនការកាន់កាប់ដីព្រៃឈើ | ✓ | | ការធ្វើចំការដំណាំ កន្លែងកំសាន្ត លំនៅដ្ឋាន |

Draft

| | | | |
|---|---|---|---|
| ដីឧទ្យានជាតិ ដែរទេ? | | | ។ល។ |
| • ទំនាស់លើសិទ្ធិផ្គត់ផ្គង់ទឹក និងទំនាស់នានាទាក់ទិន នឹងសង្គម ដែរទេ? | ✓ | | មានតិចតួចលើគុណភាពប្រភពទឹករបស់រដ្ឋាករទឹក ខេត្តកំពត (តំបន់ទឹកឈូ) |
| • ថយចុះទិន្នផលពីការចាប់ត្រី ដោយការពន្លិចស្ទឹង ទន្លេជ្រៅវែង និងទាក់ទងនឹងការលិចលង់ប្រឡាយ ហើយជាលទ្ធផល រំខាន/ឧបសគ្គដល់ការបង្កកំនើត និងការបង្កើតកូនរបស់ត្រី ដែរទេ? | ✓ | | [redacted] |
| • ដំណើររីកសាយនៃវារីជាតិឥតប្រយោជន៍ក្នុងអាង និងនៅខ្សែទឹកខាងក្រោមធ្វើឱ្យថយចុះ រំហូរទឹកចេញពីទំនប់ដែរទេ ? | ✓ | | អាចនឹងមានវារីជាតិឥតប្រយោជន៍ក្នុងអាងទីមួយ នៅប៉ុន្មានឆ្នាំដំបូង ។ |
| • ការស៊ីច្រោះដីបាតស្ទឹង/ទន្លេ នៅខាងក្រោមទំនប់ ដែរទេ ? | ✓ | | អាចនឹងមាន ព្រោះតំបន់ភ្នំកំចាយជាសិលាកំទេចកំណ និងមានល្បាយដី ។ |
| • កំនើនឧប្បត្តិហេតុនៃជំងឺកើតពីទឹក ឬជំងឺទាក់ទងនឹងទឹកដែរទេ ? | ✓ | | អាចនឹងមានក្នុងអាងទីមួយ ដោយការពុករលួយនៃរុក្ខជាតិ និងជាជំរក និងកន្លែងបង្កកំនើតរបស់សត្វមូសខ្យង់ខ្មៅ និងសត្វល្អិតចង្រៃមួយចំនួន ។ |
| • ភាពហិនអស់អុកស៊ីសែនរលាយ ដោយកំទេចពុករលួយយ៉ាងច្រើននៃរុក្ខជាតិ ត្រីងាប់ ដោយសារការ ថយចុះនៃអុកស៊ីសែនរលាយក្នុងទឹក , ការរីកដាល អាល់ហ្គេ បង្កឱ្យមានអឺត្រូហ្វីខេសិន ដែរទេ ? | ✓ | | អាចនឹងមានទូទៅក្នុងអាងទីមួយនៅប៉ុន្មានឆ្នាំដំបូង និងនៅផ្នែកជ្រៅនៃអាងជារៀងរហូត ។ |
| • ថមថយគុណភាពទឹកក្នុងអាង ដែរទេ ? | ✓ | | អាចនឹងមានទូទៅក្នុងអាងទីមួយ នៅប៉ុន្មានឆ្នាំដំបូង ។ |
| • ថយចុះ ឬ ផ្លាស់ប្តូរជលផលនៅខាងក្រោមអាង ដោយសារបន្ថយរំហូរ និងជំនន់អតិបរមា ព្រមទាំងបំរែបំរួល គុណភាពទឹក ដែរទេ ? | ✓ | | [redacted] |
| • បាត់បង់ប្រភេទត្រីបំលាស់ទី ដោយសារការរារាំង បង្អាក់នៃទំនប់ទាំងពីរដែរទេ ? | ✓ | | យោងតាមប្លង់គំរោង ពុំឃើញមានកន្លែងឱ្យត្រីឆ្លងកាត់ពីខ្សែទឹកក្រោមទៅខ្សែទឹកខាងលើឡើយ ។ |
| • បង្កើតការរងកកដីនៅច្រកចូលអាងបង្កឱ្យមានឥទ្ធិពលទឹកហូរបញ្ច្រាស់ និងការលិចលង់នៅខ្សែទឹក ខាងលើ ដែរទេ ? | ✓ | | ចំណោទភ្នំសងខាងស្ទឹងកំចាយ មានសភាពចោទខ្លាំង និងតំបន់នេះមាន ភ្លៀងធ្លាក់ខ្លាំងជារៀងរាល់ឆ្នាំ ហើយភូគព្ភសាស្ត្រតំបន់ នេះជាសិលាងាយរងនូវសំណឹកទៀតផង ។ |
| • ការរងកកដីនៅក្នុងអាង និងការបាត់បង់សមត្ថភាព ស្តុកទឹក | ✓ | | ចំណោទភ្នំសងខាងស្ទឹងកំចាយមានសភាព |

Draft

| | | | |
|---|---|---|---|
| ដែរទេ ? | | | ចោទខ្លាំង និងតំបន់នេះមាន ភ្លៀងធ្លាក់ខ្លាំង ជារៀងរាល់ឆ្នាំហើយភូគព្ភសាស្ត្រតំបន់នេះជាសិលាងាយរងនូវសំនឹកទៀតផង ។ |
| • ការផ្លាស់ប្តូរគុណភាពទឹក ដោយរំហួតក្នុងអាង , សីតុណ្ហភាពទាបអំឡុងពេលរំហូរតិច , ការប្រមូលល្បប់ក្នុងចរន្តទឹក , ភាពរលាយអុកស៊ីសែនទាប , និងកំរិតជាតិដែក និងម៉ង់កាណែសខ្ពស់ ដែរទេ ? | ✓ | | [redacted] |
| • ភាពប្រែនៃដីទំនាបលិចទឹក និងទឹកប្រៃឈ្វានពាន មាត់ពាម និងខ្សែទឹកខាងលើ ដែរទេ ? | ✓ | | អាចនឹងមានដោយសាររំហូរទាបពេក ចេញពី ១គំរោង ។ |
| • បន្ថយទំនាបលិចទឹកសំរាប់កសិកម្ម ដែរទេ ? | | ✓ | |
| • បញ្ហាបរិស្ថានកើតមានឡើងពី គ្មានការត្រួតពិនិត្យជនដែលផ្ទេរបំលាស់ទីចូលក្នុងតំបន់ , មានផ្លូវចេញ ចូលស្រួល និងមានខ្សែបណ្តាញគ្រប់គ្រាន់ ដែរទេ ? | ✓ | | អាចនឹងមាន ដោយសារសកម្មភាពគំរោង ធ្វើឱ្យតំបន់នេះមានការរីកចំរើន និងមាន ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ។ |

## ៧.៣ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

Negative Environmental Impacts and Mitigation Measures

គំរោងវារីអគ្គិសនីកំចាយមានទីតាំងនៅក្នុងតំបន់ឧទ្យានជាតិបូកគោ ដែលនៅទីនោះគ្របដណ្តប់ដោយព្រៃស្រោងភាគច្រើន ហើយដែលជាកន្លែងរស់នៅរបស់បក្សីមានប្រមាណ ៦៨ប្រភេទ ថនិកសត្វ៣៧ប្រភេទ ល្មូន២៣ប្រភេទ និងមច្ឆជាតិ (១៥ប្រភេទនៅផ្នែកខាងលើទំនប់ និង១៧ប្រភេទនៅខាងក្រោមទំនប់) ត្រូវបាន រកឃើញនៅក្នុងឧទ្យាននេះ យោងតាមការសិក្សាដោយប្រើសត្វព្រៃរបស់ក្រុមការងារ ។ ម្យ៉ាងវិញទៀត ខ្សែទឹកខាងក្រោម នៃគំរោងកំចាយនេះ ជាតំបន់រមណីយដ្ឋានទេសចរណ៍" ទឹកឈូ" និងតំបន់មាត់ពាម (តំបន់ទឹកភ្លាវ) នៃព្រែកកំចាយ និងចុង បញ្ចប់ គឺតំបន់ឆ្នេរក្នុងខេត្តកំពត ដែលនៅទីនោះសំបូរទៅដោយស្មៅសមុទ្រ ផ្កាថ្ម មច្ឆជាតិ ព្រៃលិចទឹក និងកោងកាង ។ ជីវិត និងជីវៈចំរុះនៅក្នុងសមុទ្រមានបង្គា ក្តាមគ្រប់ប្រភេទ ខ្យងគ្រប់ប្រភេទ បង្កង ត្រីតូចធំគ្រប់ប្រភេទ ហើយប្រភេទជីវរស់ក្នុង សមុទ្រកម្ពុជា ដែលត្រូវការពារដូចមានបង្ហាញនៅជំពូក៥ ។

**តារាង ៦៦ : ការប៉ាន់ប្រមាណតម្លៃសេដ្ឋកិច្ចនៃការបាត់បង់ព្រៃឈើក្នុងតំបន់គំរោង:**

| Item | ការប៉ាន់ប្រមាណ (USD) | ទំហំ(ha.) | សរុប (USD) | ផ្សេងៗ |
|---|---|---|---|---|
| ព្រៃស្រោង | ៣៧៥ (១) | ១៤២២,១៦ | ៥៣៣៣១០ | |
| ព្រៃល្បាយឬស្សី | ៥៣,៦ (២) | ៤១៦ | ២២២៩៧,៦ | |
| សរុប(USD) | | | ៥៥៥៦០៧,៦ | |

*(១) ជាព័ត៌មានBaseline survey ដែលបានសិក្សា និងចេញផ្សាយដោយ CDRI ឆ្នាំ២០០៦*

*(២) មានបង្ហាញនៅក្នុងជំពូក២*



Draft

យោងតាមឯកសាររចនាប្លង់គំរោង និងទីតាំងភូមិសាស្ត្រតំបន់កំចាយ ឃើញថា: ទីតាំងគំរោងនឹងមានការប៉ះពាល់ដល់ឧទ្យានជាតិបូកគោ និងតំបន់មាត់ពាម (តំបន់ទឹកភ្លាវ) នៃព្រៃកកំចាយ ឬព្រៃកកំពង់បាយ ហើយផលប៉ះពាល់អវិជ្ជមានដែលនឹងកកើតចេញ ពីសកម្មភាព គំរោងតាមដំណាក់កាលនិមួយៗ មានពណ៌នាតាមលំដាប់លំដោយខាងក្រោមនេះ ។

### ៧.៣.១ ដំណាក់កាលរចនាគំរោង (Project Design)

ក្នុងដំណាក់កាលនេះគំរោងពុំ មានសកម្មភាពដែលបង្កឱ្យមានផលប៉ះពាល់ធំដុំឡើយ ។ ដំណាក់កាលរចនាគំរោងគឺ មានអ្នកជំនាញការតាមផ្នែកបច្ចេកទេសធ្វើការសិក្សាស្រាវជ្រាវ ទៅតាមជំនាញបច្ចេកទេសរៀងៗខ្លួន ដើម្បីរចនាប្លង់គំរោងតាមសមាសភាពនិមួយៗឱ្យបានល្អប្រសើរ ។ ការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗដល់ធនធានបរិស្ថាន និងសង្គម រួមមានដូចតទៅ :

**ក. ធនធានរូបសាស្ត្រ**

- **ការគ្រោង[redacted]**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

អាចមានផលប៉ះពាល់របបទឹកស្ទឹងកំចាយធ្វើឱ្យខូចតំបន់ជីវៈចំរុះតាមដងស្ទឹង តំបន់ខាងក្រោមទំនប់ទី១ និងទី២ ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុនមានគំរោងធ្វើការបញ្ចេញទឹកពីអាងទី១ ចំនួន៤,៥៦-៦ម$^3$/វិន. ឥតដាច់ទាំងប្រាំង និងវស្សាតាមអគារថាមពលទី៣ និងពីអគារថាមពលទី២នៃអាងទី២ មិនតិចជាង ១០ ម$^3$/វិន ឡើយនៅដំណាក់កាលប្រត្តិបត្តិ និងថែទាំ។ ប៉ុន្តែនៅ២ឆ្នាំដំបូងក្នុងរយៈពេលប្រតិបត្តិ និងថែទាំគំរោង ក្រុមហ៊ុនត្រូវធ្វើការបិទទ្វារទឹកដើម្បីបំពេញអាងក្នុងនោះនៅឆ្នាំទី១ ត្រូវការរយៈពេលពី ៤ ទៅ ៥,៥ខែ ក្នុងការបំពេញទឹកក្នុងអាងឱ្យដល់នីវ៉ូ EL:១៥១ម ដើម្បីដំណើរការទួរប៊ីនចំនួន៤ (អគារថាមពលទី១ គឺ ១៨០ MW និងអគារថាមពលទី៣ គឺ ៤MW នៅជាប់នឹងទំនប់ទី១) ។ [redacted]ផងដែរ នៅ១ឆ្នាំ ដំបូងក្នុងរយៈពេលប្រតិបត្តិ និងថែទាំគំរោងក្រុមហ៊ុន ត្រូវធ្វើការបិទទ្វារទឹកដើម្បីបំពេញអាង ដែលត្រូវការរយៈពេល ៣ ទៅ ៥ខែ ក្នុងការបំពេញទឹកក្នុងអាងឱ្យដល់នីវ៉ូ EL:២៥ម ដើម្បីដំណើរការទួរប៊ីនចំនួន ៤ទួរប៊ីន (៣,១ MW x ៣ + ០,៨ MW) ។ ទោះបីជាយ៉ាងណាក៏ដោយក្រុមហ៊ុននឹងបញ្ចេញទឹកមិនឱ្យតិចជាង០,៣ម$^3$/វិនាទី ឥតដាច់នាខែប្រាំងដើម្បីរក្សាជីវសាស្ត្រនៅខាងក្រោមទំនប់ទី២ ។

- **ការហូរច្រោះ និងគុណភាពដី**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

អាចមានផលប៉ះពាល់ខ្លះៗដល់គុណភាពដី បណ្តាលមកពីការហៀរ ឬកំពប់ប្រេង និងការបោះកាកសំណល់ផ្សេងៗដោយបុគ្គលិក-កម្មកររបស់គំរោងក្នុងពេលសិក្សា ។

ការហូរច្រោះដីពុំមានឡើយដោយសារក្រុមហ៊ុនពុំបានឈូសឆាយ និងពង្រាបដីដើម្បីសិក្សាឡើយ ។

➢ **វិធានការណ៍កាត់បន្ថយ**

ការផ្ទុកប្រេងឥន្ទនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន ដោយប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាពល្អ មិនលេចហូរប្រេងមកលើដីក្នុងតំបន់គំរោងឡើយ ។

Draft

លើសពីនេះ ក្រុមហ៊ុននឹងធ្វើការគ្រប់គ្រងកាកសំណល់ប្រេងឱ្យបានត្រឹមត្រូវ។ រីឯកាកសំណល់រឹងចេញពីកន្លែងស្នាក់នៅរបស់កម្មករ/បុគ្គលិកវិញក្រុមហ៊ុននឹងរៀបចំធុងសំរាម និងរៀបចំកន្លែងទុកដាក់សំរាមនៅទីតាំងដែលមានសុវត្ថិភាពល្អ។

- **ការបំពុលទឹក**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅខណៈពេលនៃការសិក្សានេះដែរ ប្រភពទឹកនៃស្ទឹងកំចាយអាចនឹងមានផលប៉ះពាល់តិចតួច ដោយសារការបង្ហូរកាកសំណល់រាវចេញពីផ្ទះបាយ និងការបន្ទោរបង់របស់បុគ្គលិក-កម្មករគំរោងចូលក្នុងទឹក។

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យ ដោយជីករណ្តៅដាក់លូ ដើម្បីស្តុកលាមកមានជំរៅពី ២,៥ ទៅ ៣,៥ ម ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញ គឺមិនបង្ហូរ ឬចាក់ចូលទៅក្នុងស្ទឹងកំចាយទេ គឺជីករណ្តៅ ជំរៅ១-២ ម ទំហំ ៤-៦ម² ដើម្បីធ្វើឱ្យកាកសំណល់នោះក្លាយជាជីកំប៉ុស្តិ៍បានថែមទាំងមានធុងទុកសម្រាប់ដាក់សំរាម និងកន្លែងដុតសំរាមចោលដោយសុវត្ថិភាព។

ម្យ៉ាងវិញទៀត ក្រុមហ៊ុននឹងធ្វើការណែនាំបុគ្គលិក/កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សំរាមដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង។

- **សំលេង និងរំញ័រ**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលគ្រោងរចនាគំរោងនេះអាចមានការប៉ះពាល់តិចតួច ដោយសារមានការខួងដីសម្រាប់សិក្សាអំពីគ្រឹះទំនប់ ហើយសកម្មភាពនៃការខួងដីនេះត្រូវការកម្មករជាច្រើននាក់បង្កឱ្យមានសំលេងអ៊ូរអរ និងសន្ទឹកសំលេងម៉ាស៊ីន ហើយនឹងរំញ័របង្កឱ្យមានការរំខានដល់សត្វព្រៃ។

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងប្រើម៉ាស៊ីនខួងដីដែលមានកម្រិតរញ្ជួយ និងសំលេងតិចដើម្បីកាត់បន្ថយសំលេង និងរំញ័រដែលរំខានដល់សត្វព្រៃ។
មួយវិញទៀត ក្រុមហ៊ុននឹងមិនធ្វើការពេលយប់ទេ ដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃ។
បន្ថែមពីនេះ ក្រុមហ៊ុននឹងអប់រំកម្មកររបស់គំរោងមិនឱ្យមានការស្រែក ឬជជែកគ្នាខ្លាំងៗ រំខានដល់សត្វព្រៃ ។

**ខ.ធនធានជីវសាស្ត្រ**

- **តំបន់ឧទ្យានជាតិព្រះមុនីវង្ស (បូកគោ)**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់គ្រោងរចនាសម្រាប់សាងសង់ទំនប់ទប់ទឹកអាងទាំងពីរ អគារថាមពលទាំងពីរ បំពង់ទូនែល ខ្សែចំលងចរន្ត២៣០ kV (ប្រវែង១១,០៥ kV) និងហេដ្ឋារចនាសម្ព័ន្ធនានារបស់គំរោងវារីអគ្គិសនីកំចាយនេះអាចនឹងធ្វើឱ្យប៉ះពាល់តំបន់ឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) ដែលគ្រប់គ្រងដោយបង្កឱ្យមានការប៉ះពាល់ដល់ប្រភេទព្រៃឈើ និងសត្វព្រៃនៅក្នុងតំបន់ការពារនេះខ្លះដែរ ដោយសារតែសកម្មភាពសិក្សាគំរោង។ រីឯខ្សែបញ្ជូនចរន្ត ២៣០ kV វិញមានប្រវែងសរុប ១១,០៥គ.ម. អាចនឹងប៉ះពាល់ដល់តំបន់ឧទ្យានជាតិប្រវែង ៤,៨៣ គ.ម. ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)។

ដោយសារសកម្មភាពសិក្សាគំរោងនឹងបង្កឱ្យមានផលប៉ះពាល់ដល់អេកូឡូស៊ីដូចជា: សំលេងពីគ្រឿងចក្រ ភាពខ្សៀវខ្សារនៃក្រុមបុគ្គលិក-កម្មករ ការទន្រ្ទានចូលក្នុងព្រៃពីក្រុមបុគ្គលិក-កម្មករ ក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬការជួញដូរសត្វព្រៃសម្រាប់ធ្វើម្ហូប និងកាប់ឈើលក់ឱ្យឈ្មួញជាដើម ។ល ។

[redacted]

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ក្បែរខាង ។ រីឯ ខ្សែបញ្ជូន ចរន្ត២៣០ kV ប្រវែង ១១,០៥ គ.ម. វិញ គឺមិនទាន់មានសកម្មភាពអ្វីទេ គឺគ្រាន់តែចុះសិក្សាតម្រង់ទិសប៉ុណ្ណោះ ។ (មានលម្អិតនៅ ជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)

ជាងនេះទៅទៀត ក្រុមហ៊ុននឹងធ្វើការអប់រំដល់កម្មករគំរោងមិនឱ្យធ្វើការទន្រ្ទានព្រៃក្នុងតំបន់គំរោងដើម្បីចាប់ ឬបរបាញ់សត្វព្រៃ ឬជួញដូរសត្វព្រៃសម្រាប់ធ្វើម្ហូប និងកាប់ព្រៃឈើលក់ឱ្យឈ្មួញឡើយ ហើយដាក់វិន័យយ៉ាងតឹងរ៉ឹងដល់ពួកគេ ដែលប្រព្រឹត្តខុសទៅនឹងបំរាមនេះ។ រីឯស្បៀង និងម្ហូបអាហារក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃ ។ ក្រុមហ៊ុននឹងនាំ ស្បៀងពីទីរួមខេត្តកំពត ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិក-កម្មករគំរោង ឱ្យយល់ពីច្បាប់នៃការគ្រប់គ្រងថែរក្សាធនធាន និងសត្វព្រៃនៅក្នុងតំបន់ការពារ ។ ដោយដាក់ផ្លាកសញ្ញាព្រៃការពារ និងហាមបបាញ់ជាអក្សរខ្មែរ និងចិនឱ្យបានច្រើនដើម្បីឱ្យប្រជាពលរដ្ឋ និង ចិនងាយមើល ឃើញ ។

[redacted]

• **ធនធានព្រៃឈើ និងជំរកសត្វព្រៃ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់គ្រោងរចនានេះ អាចប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ ដោយសារការកាប់កូនឈើធ្វើស្តាន និងរានព្រៃធ្វើ ។ ម្យ៉ាងវិញទៀតវាអាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ដោយសារសកម្មភាពសិក្សាគំរោង ។ អាចមានការបរបាញ់ ឬជួញដូរសត្វព្រៃ និងកាប់ឈើខុសច្បាប់ពីសំណាក់កម្មករគំរោងដែលធ្វើប៉ះពាល់ដល់ជំរកសត្វព្រៃ ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ដើម្បីកាប់ឆ្ការព្រៃឈើធ្វើផ្លូវ និងប្រើប្រាស់ឈើសម្រាប់សាងសង់ស្ពានឆ្លងកាត់ ។

ម្យ៉ាងវិញទៀត ក្រុមហ៊ុននឹងបោះជំរុំការងារនៅនឹងកន្លែងជៀសវាងការដឹកសំភារៈការងារចុះឡើងបង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ ។

លើសពីនេះ ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃ ។

បន្ថែមពីនេះ ក្រុមហ៊ុននឹងសហការជាមួយជំនាញក្រសួងបរិស្ថានជួយណែនាំដល់បុគ្គលិក/កម្មករគំរោងឱ្យមានការយល់ដឹងអំពីការការពារ និងថែរក្សាសត្វព្រៃ ។

ជាពិសេស ក្រុមហ៊ុននឹងសហការជាមួយជំនាញរដ្ឋបាលព្រៃឈើដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ ។

• **ជីវសាស្ត្រសត្វព្រៃ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលរចនាគំរោងនេះ អាចប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពសិក្សាគំរោង ។



Draft

លើសពីនេះ អាចមានការបរបាញ់ ឬជួញដូរសត្វព្រៃ និងកាប់ឈើខុសច្បាប់ពីសំណាក់កម្មករគំរោង ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងបោះជំរុំការងារនៅនឹងកន្លែងជៀសវាងការដឹកសំភារៈ ការងារ ចុះឡើងបង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ ។ មួយវិញទៀត ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងសហការជាមួយជំនាញក្រសួងបរិស្ថានជួយណែនាំដល់បុគ្គលិកកម្មករគំរោងឱ្យមានការយល់ដឹងអំពីការការពារ និងថែរក្សាសត្វព្រៃ។

ចំពោះម្ហូបអាហារក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃ។ ក្រុមហ៊ុននឹងនាំស្បៀងពីទីរួមខេត្តកំពតដើម្បីផ្គត់ផ្គង់ ។

ម្យ៉ាងវិញទៀត ក្រុមហ៊ុននឹងដាក់បញ្ចូលថវិកា ១៧.៥០០.០០០ USD ដុល្លារអាមេរិក ដើម្បីការពារបរិស្ថាន រួមទាំងបង្កើតស្ថានីយន៍ ចិញ្ចឹមត្រីដែលងាយរងគ្រោះថ្នាក់។ (លម្អិតមើលនៅ EMP)

. **ជីវសាស្ត្រដែលរស់នៅក្នុងទឹក/មច្ឆជាតិ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដោយតាមគំរោងប្លង់សម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីស្ទឹងកំចាយនេះ គឺពុំមានរចនាប្លង់គំរោងសម្រាប់ឱ្យត្រីឆ្លងកាត់នោះទេ ដែលជាហេតុធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់ចរាចរត្រី នៅពេលដែលគំរោងទាំងមូលនឹងសាងសង់ និងដំណើរការ ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាប្លង់គំរោងដោយរួមបញ្ចូលនូវសំណង់សិល្បៈការសម្រាប់ឱ្យត្រីឆ្លងកាត់បាន បើមានការសិក្សារកឃើញថាមានប្រភេទត្រីជាច្រើនប្រភេទមានប្រយោជន៍ដល់សេដ្ឋកិច្ច ដើម្បីបំលាស់ទីក្នុងការបន្តពូជ ពីខ្សែទឹកខាងក្រោមទៅខ្សែទឹកខាងលើ ឬពីខ្សែទឹកខាងលើមកខ្សែទឹកខាងក្រោមវិញនៃស្ទឹងកំចាយនេះ ព្រមទាំងមានការស្នើសុំពីរាជរដ្ឋាភិបាល និងអ្នកឯកទេសជលផលជាតិ ។

ក៏ប៉ុន្តែក្រុមហ៊ុននឹងមានវិធានការណ៍ដើម្បីជំនួសសំណង់សិល្បៈការសម្រាប់ឱ្យត្រីឆ្លងកាត់នេះ ដោយបង្កើតស្ថានីយ៍ចិញ្ចឹមត្រី (រីសពូជក្នុងតំបន់ក្លួចធ្វើការព្រលែងវាចូលក្នុងអូរស្ទឹងធម្មជាតិដែលមានលក្ខណៈទីជំរកប្រហាក់ប្រហែលគ្នា ។ [redacted]

**គ. ធនធានសេដ្ឋកិច្ចសង្គម**

. **ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលគ្រោងរចនានេះ អាចនឹងប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ ដោយសារខ្លាចបាត់បង់ដីស្រែចំការ និងលំនៅដ្ឋានដោយសារការបាក់ទំនប់ ។ រីឯប្រជាពលរដ្ឋដែលស្ថិតនៅក្រោមគន្លងខ្សែបញ្ជូនចរន្ត ២៣០kV ប្រវែង ១១.០៥ គ.ម ទាំង ៤ ភូមិមានសតិអារម្មណ៍ខ្លាចប៉ះពាល់ដល់សុវត្ថិភាពពួកគេក្រោយពេលសាងសង់រួច ។ (មានលម្អិតនៅជំពូក៥ និង៨)

អាចនឹងមានអ្នកចំណូលថ្មីមកតាំងទីលំនៅក្នុងតំបន់គំរោងបន្ថែម ដើម្បីកេងចំណេញដោយសារការអភិវឌ្ឍនេះបង្កការលំបាកដល់ក្រសួងបរិស្ថាន និងក្រុមហ៊ុន ។

Draft

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ដូចជា អាជ្ញាធរមូលដ្ឋាន មន្ទីរ និងក្រសួងពាក់ព័ន្ធដើម្បីផ្សព្វផ្សាយពន្យល់ដល់ប្រជាពលរដ្ឋ ដែលរស់នៅខាងក្រោមតំបន់គំរោង ។

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយ និងជូនដំណឹងដល់សាធារណជន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋជាមុនអំពីគោលបំណងជាក់ស្តែងរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍគំរោងនេះនៅពេលអនាគត ។

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ការទន្ទ្រានដីព្រៃ ដែលជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ។

ក្រុមហ៊ុននឹងធ្វើការកាត់បន្ថយការធ្វើឱ្យលួក់ខ្លាំងដោយសាងសង់ទំនប់បណ្តោះអាសន្នព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់ ។

ក្រុមហ៊ុននឹងធ្វើការគ្រោងរចនាគំរោង ដោយគណនាគ្រឹះសំណង់ និងតួទំនប់ឱ្យបានរឹងមាំតាមលក្ខណៈបច្ចេកទេស ជាពិសេសគណនាអាយុនៃសំណង់ធ្វើអំពីបេតុងឱ្យបានយ៉ាងតិច៩០ឆ្នាំក្នុងលក្ខណៈធម្មតា (ប្រសិនបើមិនមាន គ្រោះធម្មជាតិ ឬសង្គ្រាម) ។

ចំពោះអ្នករស់នៅក្រោមខ្សែបញ្ជូនចរន្តទាំងអស់ ក្រុមហ៊ុននឹងព្យាយាមបញ្ចៀសឱ្យអស់លទ្ធភាពដើម្បីកុំឱ្យប៉ះផ្ទះតែបើសិនជាមិនអាចធ្វើបានក្រុមហ៊ុននឹងជូនសំណង ដើម្បីរុះរើផ្ទះដោយតម្លៃសមស្រប ។

ក្រុមហ៊ុននឹងធ្វើការចរចារដើម្បីទូទាត់ជាថវិកាជូនប្រជាពលរដ្ឋដែលប៉ះពាល់ទាំងនេះ ។

- **ទំនាស់នៃសិទ្ធិប្រើប្រាស់ដីនៃតំបន់គំរោង**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលរចនាគំរោងនេះអាចនឹងមានជនឆ្លៀតឱកាសដើរបំផុសប្រជាពលរដ្ឋ ក្នុងគោលបំណងចង់ទាមទារផលប្រយោជន៍មិនសមហេតុផល ដើម្បីធ្វើការទាមទារសំណងពីក្រុមហ៊ុន ។

បន្ថែមពីលើនេះទៀតអាចនឹងមានជនឆ្លៀតឱកាសបំផុសប្រជាជនឱ្យចាប់ដីនៅក្នុងតំបន់គំរោងដែលជាតំបន់ការពាររបស់ឧទ្យានជាតិព្រះបុនីវង្សនៃក្រសួងបរិស្ថានធ្វើឱ្យបាត់បង់ធនធានព្រៃឈើកាន់តែច្រើន ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ក្នុងការបំផុសចលនាប្រជាពលរដ្ឋរបស់ជនឆ្លៀតឱកាសក្នុងគោលបំណងទាមទារដីធ្លី និងសំណងផ្សេងៗ មិនយោងទៅតាមច្បាប់ឱ្យទាន់ពេលវេលា ពីព្រោះតំបន់គំរោងវារីអគ្គិសនីស្ទឹងកំចាយនេះនៅឆ្ងាយក្នុងតំបន់ការពាររបស់ឧទ្យានជាតិព្រះមុនីវង្ស នៃក្រសួងបរិស្ថាន ។

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរបរិស្ថានខេត្តកំពតដើម្បីចាត់វិធានការទប់ស្កាត់ និងបង្កើនកំលាំងការពារតំបន់នេះ ។

- **ប្រពៃណី វប្បធម៌ និងសាសនា**

➢ ហេតុប៉ះពាល់អវិជ្ជមាន

អាចមានការប៉ះពាល់ប្រពៃណី វប្បធម៌ និងសាសនា ព្រោះតែមានបុគ្គលិកជនជាតិបរទេសចុះមកសិក្សានៅក្នុងតំបន់គំរោងដែលមិនមានការយល់ដឹងអំពីប្រពៃណី វប្បធម៌ និងសាសនារបស់ប្រជាពលរដ្ឋនៅតំបន់នេះ ។

Draft

➢ **វិធានការកាត់បន្ថយ**

ដោយសារដំណាក់កាលនេះគ្រាន់តែជាការចុះសិក្សាដំបូង បុគ្គលិក-កម្មករបរទេសក៏មានចំនួនតិចតួចដែរ ក៏ប៉ុន្តែក្រុមហ៊ុននឹងអប់រំអ្នកទាំងនោះអំពីប្រពៃណី វប្បធម៌ និងសាសនារបស់ប្រជាពលរដ្ឋនៅតំបន់នេះ ។

ជាងនេះទៅទៀតក្រុមហ៊ុននឹងមិនអនុញ្ញាតឱ្យកម្មករ បុគ្គលិករបស់ខ្លួនចេញពីការដ្ឋានដោយគ្មានការអនុញ្ញាតឡើយ ។

- **ផ្លូវគមនាគមន៍**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលនេះ អាចមានការប៉ះពាល់ និងគ្រោះថ្នាក់ដល់អ្នកសិក្សា ឬធ្វើឱ្យស្ទះការងារសិក្សាប្លង់រចនាគំរោងដោយសារមិនមានផ្លូវដឹកជញ្ជូនច្បាស់លាស់សម្រាប់គំរោងនេះ ដែលមានចំណោទខ្លាំង ហើយឆ្លងកាត់ផ្ទាំងថ្ម (ពីទំនប់ទី២ដល់ទំនប់ទី១ និងចូលទៅក្នុងអាងទឹកទី១) ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងរកអ្នកនាំផ្លូវរស់នៅក្បែរតំបន់គំរោង ដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ដែលធ្លាប់ចេញចូលតំបន់នេះ ។

លើសពីនេះ ក្រុមហ៊ុននឹងត្រួសត្រាយផ្លូវ និងធ្វើស្ពានបណ្ដោះអាសន្ន ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងជួលរថយន្តដែលមានសុវត្ថិភាពល្អក្នុងការសិក្សាគំរោងនេះ ។

- **សុខភាពសាធារណៈ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅដំណាក់កាលនេះ អាចនឹងបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក កម្មកររបស់ក្រុមហ៊ុន ដោយសារតំបន់នេះស្ថិតនៅក្នុងព្រៃដែលបង្កឱ្យមានកើតជំងឺគ្រុនចាញ់ គ្រុនសន្និ ។ល ។

នៅក្នុងពេលសិក្សានេះអាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក កើតជំងឺរាគរូស ឬអាសន្នរោគ ព្រោះនៅតំបន់នេះមិនមានប្រព័ន្ធទឹកស្អាត ។

ក្នុងដំណាក់កាលរចនាគំរោងនេះដោយសារការបន្ទោរបង់ដាក់ទឹក និងធ្វើបង្គន់លើទឹករបស់កម្មករ អាចធ្វើឱ្យកម្មករផ្សេងទៀតមានជំងឺគ្រុនពោះវៀន អាសន្នរោគ រាគរូស ។ល ។

ម្យ៉ាងទៀតប្រជាពលរដ្ឋក្បែរតំបន់គំរោងអាចឆ្លងជំងឺកាមរោគពីបុគ្គលិក-កម្មករដែលមកពីកន្លែងផ្សេងៗ និងជំងឺអេដស៍ជាដើម ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកកម្មករទាំងសុខភាពអនាម័យ ការការពារជំងឺសង្គម និងការហូបទឹកឆ្អិន ។

ក្រុមហ៊ុននឹងអប់រំបុគ្គលិកកម្មករ អំពីវិធីការពារ និងការទប់ស្កាត់ បញ្ហាជំងឺទាំងនេះរាល់បីខែម្ដង ។

ក្រុមហ៊ុននឹងត្រៀមថ្នាំបង្ការ ដើម្បីការពារ និងព្យាបាលជំងឺទាំងនោះ ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យ ដោយជីកដីដាក់លូត្រឹមត្រូវឱ្យឆ្ងាយពីប្រភពទឹក ។

- **ហានិភ័យ (Risk)**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

អាចមានគ្រោះថ្នាក់ដោយសារតំបន់នោះមិនដែលស្គាល់ភូមិសាស្ត្រ ដូចជាៈ ជ្រោះជ្រៅ, ការបាក់ផ្ទាំងថ្មធំៗ, ចំណោទខ្ពស់ៗបង្កឱ្យគ្រោះថ្នាក់ដោយរអិល, គ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះបង្កប់ក្នុងដី ។

Draft

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋានដោយ មានការសហការជាមួយសមត្ថកិច្ច និងអង្គភាពកំចាត់មីន ដើម្បីធ្វើការដោះគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងនេះចេញពីតំបន់គំរោង ។

### ៧.៣.២ ដំណាក់កាលសាងសង់ ( ការត្រៀមរចនាគំរោង)

[redacted]

### ក.ធនធានរូបសាស្រ្ត

- **សណ្ឋានដី និងឋានលេខា (Morphology and Topography)**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់នៃការសាងសង់គំរោងនេះ អាចនឹងបណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគំរោង ដោយសារសកម្មភាពការឈូសឆាយ និងពង្រាបដីស្រទាប់លើដែលមានគំរបព្រៃ ដើម្បីធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ដូចជា ការធ្វើផ្លូវ (*ទាំងផ្លូវដឹកសម្ភារៈ ថ្ម ដែក ស៊ីម៉ង់ត៍ សំរាប់ការសាងសង់ទំនប់ អគារថាមពល និងហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី ព្រមទាំងការធ្វើផ្លូវចូលទៅបង្គោលភ្លើងទាំង៣៤*) សាងសង់ទំនប់ ប្រឡាយដោះទឹក បំពង់ទួនេល អគារថាមពល កន្លែងយកថ្ម កន្លែងយកដី កន្លែងចាក់ចោលដី និងសំណល់ថ្ម កន្លែងសាងសង់អគារ សម្រាប់ទីស្នាក់ការ និងផ្ទះបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ។ល ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការជួសជុលទីតាំងយកថ្មកន្លែងយកដី និងកន្លែងចាក់ដីចោលឱ្យមានសុវត្ថិភាពល្អដោយដាំដើមឈើនៅទីនោះវិញក្រោយពេលសាងសង់រួច ។

ធ្វើការដាំស្មៅ ឬបាញ់ស៊ីម៉ង់ត៍ការពារការបាក់ដីនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោទផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងដទៃទៀត ដើម្បីការពារការហូរច្រោះបាក់ជញ្ជាំងភ្នំបន្ថែម ។ ម្យ៉ាងវិញទៀតក្រុមហ៊ុននឹងធ្វើការសាងសង់ផ្នែកធំៗតែរដូវប្រាំង ដើម្បីទប់ស្កាត់ការហូរច្រោះដែលនាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា ។ ( មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)

- **ការហូរច្រោះ និងគុណភាពដី**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលសាងសង់នេះអាចនឹងមានការហូរច្រោះដីដោយសារការឈូសឆាយដីគំរបព្រៃឈើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ដូចជា ការកាយជញ្ជាំងភ្នំធ្វើផ្លូវ ធ្វើទំនប់ ធ្វើអគារថាមពលជាដើម ព្រោះថាតំបន់នេះជាតំបន់ខ្ពង់រាប និងភ្នំនឹងងាយមានការហូរច្រោះដី ជាពិសេសនៅរដូវវស្សា តែតំបន់នេះជាតំបន់រងទូវទឹកភ្លៀងខ្លាំងផងដែរ ក្នុងប្រទេសកម្ពុជា ។

រីឯសកម្មភាពសាងសង់អាចនឹងបង្កឱ្យប៉ះពាល់ដល់គុណភាពដី ស្រទាប់លើនៅជុំវិញតំបន់ចោលដីស្អុយ ឬសំណល់ថ្ម ដែលធ្វើឱ្យបាត់បង់ជីជាតិរបស់ដីស្រទាប់លើនាតំបន់នោះបណ្តាលមកពីការហូរច្រោះតំបន់ដីស្អុយ ឬសំណល់ថ្មនេះទៅគ្របពីលើសណ្ឋានដីតំបន់ជុំវិញនោះ ។

➢ **វិធានាការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដី ( ការងារដី) ក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស ។

បន្ថែមពីនេះ ក្រុមហ៊ុននឹងពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើរួចដាំដើមឈើឡើងវិញក្នុងតំបន់នេះ ដោយធ្វើការសហការជាមួយក្រសួងបរិស្ថាន ។

ធ្វើការដាំស្មៅ ឬបាញ់ស៊ីម៉ង់ត៍ការពារការបាក់ដីនៅកន្លែង ដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោទផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ដទៃទៀតដើម្បីការពារការហូរច្រោះបាក់ជញ្ជាំងភ្នំបន្ថែម ។

- **ប្រព័ន្ធជលសាស្ត្រ ទឹកលើដី (ប្រឡាយ- អូរ-ស្ទឹង)** (Hydrologycal System)

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះអាចនឹងប៉ះពាល់ដល់បរិមាណធារទឹករបស់ស្ទឹងកំចាយ ដោយសារការទប់ទំនប់កាត់ស្ទឹងកំចាយដើម្បីធ្វើអាងតម្កល់ទឹក ។

បន្ថែមពីលើនេះ ការងារសាងសង់នេះក៏នឹងអាចប៉ះពាល់ដល់គុណភាពទឹក ដោយសារសកម្មភាពសាងសង់ ដូចជា ការលាងថ្មខ្សាច់ ការហូរច្រោះ ជញ្ជាំងភ្នំដែលខ្លួនបានកាយ ដែលធ្វើឱ្យទឹកស្ទឹងឡើងល្អក់ខ្លាំង ។

ម្យ៉ាងទៀតអាចនឹងប៉ះពាល់ដល់គុណភាពទឹកដោយសារការបោះបង់កាកសំណល់រឹង និងការបង្ហូរកាកសំណល់រាវពីកន្លែងរស់នៅរបស់បុគ្គលិក-កម្មកររបស់គំរោង ការលេចធ្លាយប្រេងឥន្ធនៈ ការលាងសម្អាតគ្រឿងចក្រ និងប្រេងរំអិលពីគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ និងការមុជទឹកសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់ ដែលនៅក្បែរប្រភពទឹកនឹងធ្វើឱ្យគុណភាពទឹកស្ទឹងកំចាយ និងប្រភពទឹកផ្សេងទៀតនៅតាមគន្លងខ្សែចំលងចរន្ត២៣០ kV មានការថយចុះ ។ (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋាន ដើម្បីផ្តល់ទឹកមកខ្សែទឹកខាងក្រោមឱ្យបានជាធម្មតាវិញ ។

ក្រុមហ៊ុននឹងធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយសាងសង់ទំនប់បណ្តោះអាសន្នព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់ ។ ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោទផ្សេងៗដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងដទៃទៀត រួមទាំងការធ្វើការបង្ហាប់ដីនៅតាមបង្គោលភ្លើងទាំង៣៤ ក្រោយពីសាងសង់រួច ដើម្បីការពារការហូរច្រោះបាក់ជញ្ជាំងភ្នំបន្ថែម ។

ក្រុមហ៊ុននឹងសាងសង់នៅរដូវប្រាំងដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋានដីផ្សេងៗដែលអាចហូរចូលស្ទឹង និងប្រភពទឹកផ្សេងទៀត ។

ក្រុមហ៊ុននឹងអប់រំដល់បុគ្គលិកកម្មករអំពីការបោះបង់កាកសំណល់រឹង-រាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅលើដី ដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គំរោង ។ ក្រុមហ៊ុននឹងធ្វើការណែនាំបុគ្គលិក/កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សំរាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង ។

នៅកន្លែងលាងថ្មលាយ បេតុងក្រុមហ៊ុននឹងធ្វើប្រព័ន្ធកាត់បន្ថយភាពល្អក់ដោយជីកប្រឡាយជុំវិញ រួចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ ទំហំ១០x១០x៣ម. (បណ្តោយxទទឹងxជំរៅ) បន្ទាប់មកទឹកនេះហូរចូលអាងរងកករទី២មានទំហំ១០x១៥x៣ម (បណ្តោយxទទឹងxជំរៅ) ។ ទឹកដែលបានប្រើរួចត្រូវបានបង្ហូរចូលទៅ រណ្តៅទី១ ដើម្បីឱ្យរងកករ ហើយ

Draft

បង្ហូរតទៅរណ្តៅទី២ រៀងគ្នាដោយប្រឡាយនាំទឹកដើម្បីឱ្យរងកករម្តងទៀតមុននឹងបង្ហូរចូលប្រភពទឹក ហើយកករដែលចេញមកពីការលាងនោះត្រូវបានដឹកចេញទៅទុកដាក់នៅកន្លែងចាក់អាចម៍ដីនៅតាមទីតាំងក្បែរនោះ ។

គ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬព្រែកឡើយ ដូចជាសង់បន្ទប់ទឹក និងបង្គន់អនាម័យឆ្ងាយពីស្ទឹងមានអាងសិបទិក ត្រឹមត្រូវមានកន្លែងទុកដាក់សំណល់រឹងល្អតាមបច្ចេកទេស ។

ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យដោយជីករណ្តៅដាក់លូដើម្បីស្តុកលាមក មានជំរៅពី ២,៥ ទៅ ៣,៥ ម ដើម្បីសំលាប់មេរោគ ។ ចំពោះសំណល់ផ្ទះបាយវិញ គឺមិនបង្ហូរ ឬចាក់ចូលទៅក្នុងស្ទឹងកំចាយនេះទេគឺជីករណ្តៅជំរៅ ១-២ម. ទំហំ ៤ទៅ៦ម² ដើម្បីធ្វើឱ្យកាកសំណល់នោះក្លាយជាជីកំប៉ុស្តិ៍បានថែមទាំងមានធុងទុកសម្រាប់ដាក់សំរាម និងកន្លែងដុតសំរាមចោលដោយសុវត្ថិភាព ។

- **ការរញ្ជួយដី** (seismology)

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលសាងសង់នេះអាចនឹងបង្កឡើងដោយសារការបំផ្ទុះផ្ទាំងថ្មនៅការដ្ឋានធ្វើទំនប់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅជុំវិញដោយស្ទះផ្លូវចេញចូល និងសំណង់ ឬប៉ះពាល់ដល់សុវត្ថិភាពកម្មករដូចជា: ការរញ្ជួយ បាក់ផ្ទាំងថ្មជាដើម ។ល ។ ការរញ្ជួយដោយសារការដឹកសំភារៈសំណង់ធ្ងន់ៗ (ថ្ម ខ្សាច់ ប្រើគ្រឿងរំញ័រក្នុងការបង្ហាប់បេតុង និងដឹកដុំទួរប៊ីនភ្លើង) ក្នុងការសាងសង់ទំនប់សាងសង់រន្ធទូនេល អគារថាមពល ការដឹកសម្ភារៈបង្គោលភ្លើងជាដើម ។

ការបំផ្ទុះថ្មនៅកន្លែងយកថ្ម (ដុំបជ្រឹង និងដុំបមាន់ព្រៃ) ក្នុងភូមិទ្វារថ្មី ឃុំ ព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត អាចធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពកម្មករ និងប្រជាពលរដ្ឋដែលរស់នៅជុំវិញ ។ ជាងនេះទៅទៀត ការឈូសឆាយទីតាំងយកថ្ម (ដុំបជ្រឹង និងដុំបមាន់ព្រៃ) ដើម្បីកិនបំបែកសម្រាប់ដឹកជញ្ជូន ធ្វើឱ្យប៉ះពាល់ដល់ដំណាំ និងដីចំការរបស់ប្រជាពលរដ្ឋ ។

ការដឹកជញ្ជូនថ្មពីការដ្ឋានយកថ្ម មកដល់កន្លែងលាយបេតុងមានចំងាយឆ្ងាយត្រូវកាត់តាមផ្លូវជាតិលេខ៣ បណ្តាលឱ្យខូច និងស្រុតផ្លូវនេះ ។

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមការងាររបស់ក្រុមហ៊ុននឹងកំណត់តំបន់គ្រោះថ្នាក់ ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់រួចដាក់ផ្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់ ។

ការប្រើប្រាស់គ្រឿងផ្ទុះ គឺក្រុមហ៊ុននឹងកំណត់កម្រិតរញ្ជួយ និងកំលាំងបំផ្ទុះឱ្យតូច ដែលមិនប៉ះពាល់ដល់ការបាក់ផ្ទៃកខ្លះនៃភ្នំ ឬផ្លូវដែលនៅក្បែរតំបន់បំផ្ទុះ ។ ក្រុមហ៊ុន នឹងប្រើប្រាស់រថយន្តមានកង់ច្រើនដើម្បីកាត់បន្ថយរំញ័រក្នុងការដឹកសម្ភារៈធ្ងន់ៗ ។

ក្រុមហ៊ុននឹងផ្តល់ព័ត៌មាន និងផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាន នូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋដែលរស់នៅទីនោះ ។ ជាងនេះទៅទៀត មុនធ្វើការបំផ្ទុះក្រុមហ៊ុននឹងប្រើឧបករណ៍ផ្តល់សញ្ញាជាសំលេងរយៈពេល៥-១០នាទីជាមុន ។

ក្រុមហ៊ុនជួលដីស្រែ/ចំការ និងដោះស្រាយការប៉ះដំណាំដោយតម្លៃ ៥000-១0000 ដុល្លារ/ហ.ត ដែលនៅជាប់នឹងទីតាំងយកថ្មចំងាយ ១០០ ម. ជុំវិញដើម្បីការពារការខូចខាត, ការគ្រោះថ្នាក់ និងរបួសបណ្តាលមកពីការបំផ្ទុះថ្មនេះ ។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងសងការខូចខាតនៅ ពេលដែលមានការប៉ះពាល់ក្រៅពីតំបន់ដែលក្រុមហ៊ុនបានជួល ។

ការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល ( ម៉ោង៤:00-៥:00 ល្ងាច) ។

Draft

ក្រុមហ៊ុនបានសាងសង់ផ្លូវគ្រួសក្រហម/ល្បាយថ្ម បណ្ដោះអាសន្នអមតាមផ្លូវជាតិនេះខាងឆ្វេងដៃ (តាមទិសដៅកំពត-ភ្នំពេញ) ប្រវែង ១៣៨៣០ម ទទឹងខ្នងលើ ៤ម ហើយភ្ជាប់ពីផ្លូវនេះត្រង់ផ្លូវបត់លោកយាយម៉ៅដល់ការដ្ឋានយកថ្ម ក្រុមហ៊ុនបានស្ដារផ្លូវលំចាស់ប្រវែង ៤៧៥០ម ទទឹងខ្នងលើ ៨ ម ផងដែរ។ សរុបនៃការសាងសង់ផ្លូវចេញ-ចូលរបស់គំរោងនេះមានប្រវែងសរុប ៤១,៧៦ គម. (មានលម្អិតនៅជំ[redacted]

រាល់សំភារៈសំណង់ធន់ធ្ងន់ក្រុមហ៊ុន និងធ្វើការដោះបំបែក និងផ្ទេរចែករំលែកឱ្យងាយក្នុងការដឹកជញ្ជូនវា ទោះបីត្រូវប្រើរថយន្តដឹកច្រើនជើងក៏ដោយ ។ ក្រុមហ៊ុន ក៏នឹងប្រើប្រាស់រថយន្តមានកងច្រើនដើម្បីកាត់បន្ថយរំញ័រក្នុងការដឹកសម្ភារៈធ្ងន់ៗ។

- **ការបំពុលខ្យល់**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះអាចនឹងបំពុលខ្យល់ដោយសារការដុតព្រៃឈើដើម្បីសំអាតការដ្ឋាន និងផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសំភារៈ និងការបំផ្ទុះសម្រាប់ការងារសាងសង់របស់គំរោង។

ការបំពុលខ្យល់ដោយសារធូលីដីថ្មហុយចេញពីការដឹកជញ្ជូនសំភារៈសំណង់ចេញពីការកិនបំបែកថ្មចេញពីផ្លូវ ដែលមិនបានស្រោចទឹកជាប្រចាំធ្វើឱ្យប៉ះពាល់ដល់សុខភាពកម្មករ អ្នកធ្វើដំណើរ និងសត្វរស់នៅក្បែរនោះទៀតផង។

ម្យ៉ាងទៀតអាចនឹង បំពុលខ្យល់ដោយសារភ្លើងឆេះព្រៃ បណ្ដាលមកពីការធ្វេសប្រហែសពីបុគ្គលិកកម្មករគំរោង។

អាចមានការបំពុលខ្យល់ធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ដែលរស់នៅក្បែរកន្លែងយកថ្ម (ដុបមាន់ព្រៃ និងដុបជ្រឹង) ក្នុងភូមិទ្វារថ្មី ឃុំព្រៃថ្នង មកពីសារធាតុគីមីដែលប្រើសម្រាប់ការបំផ្ទុះថ្ម។

  ➢ **វិធានការណ៍កាត់បន្ថយ**

Draft

ក្រុមហ៊ុននឹងមិនដុតព្រៃឈើទាំងអស់នៃតំបន់នឹងត្រូវលិចនោះទេតី ក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីធ្វើការសំអាតព្រៃក្នុងតំបន់ដែលនឹងត្រូវលិចដូចជាៈ ក្រសួងអាចលក់ឈើឱ្យក្រុមហ៊ុនផ្សេង ដែលក្រុមហ៊ុននេះត្រូវកែច្នៃឈើទាំងនោះឱ្យអស់លទ្ធភាពដែលអាចធ្វើទៅបាន ហើយបានថវិកាចូលរដ្ឋថែមទៀតផង។

ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានការបញ្ចេញផ្សែងតិច ដើម្បីកាត់បន្ថយការបំពុលខ្យល់ក្នុងតំបន់នោះ។

ក្រុមហ៊ុននឹងជ្រើសរើសជាតិផ្ទុះដែលមិនបង្កការបំពុលខ្យល់ខ្លាំង។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងត្រៀមឧបករណ៍ពន្លត់អគ្គិភ័យ និងមានកន្លែងបូមទឹកគ្រប់គ្រាន់នៅពេលមានអគ្គិភ័យ។

ធ្វើការស្រោចទឹកជាប្រចាំលើផ្លូវដែលខ្លួនដឹកសំភារៈ កន្លែងកិនថ្ម , ផ្លូវដឹកថ្ម និងផ្លូវដែលខ្លួនប្រើប្រាស់ ហើយធ្វើការគ្របលើដីខ្សាច់ ថ្ម ស៊ីម៉ង់ត៍ នៅពេលដែលរថយន្តទាំងនោះដឹកវាឆ្លងកាត់ភូមិអ្នកស្រុក ទីប្រជុំជនជាដើម ដើម្បីការពារកុំឱ្យកំពប់ ឬធ្លាក់ធ្វើឱ្យមានផលអាក្រក់ផ្សេងៗ។

ក្រុមហ៊ុននឹងធ្វើការបំផ្ទុះតែនៅចន្លោះម៉ោង ៤:០០-៥:០០ ល្ងាច ដែលជាពេលវេលាស្ងប់ខ្យល់។ ហើយសារធាតុគីមីដែលប្រើសម្រាប់ការបំផ្ទុះនោះគឺមានការអនុញ្ញាត ពីស្ថាប័ននគរបាលនៃក្រសួងមហាផ្ទៃកម្ពុជា។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនក៏បានជួលដីប្រជាពលរដ្ឋ ១០០ ម.ជុំវិញកន្លែងនេះ ដោយមិនអនុញ្ញាតឱ្យពួកគាត់រស់នៅក្នុងបរិវេណនេះឡើយ ដើម្បីការពារសុវត្ថិភាព។

- **ការបំពុលទឹក**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងបំពុលគុណភាពទឹកស្ទឹងកំចាយដោយសារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង បណ្តាលមកពីការខួង ឬការងារដី ការងារបេតុង ការងារបំផ្ទុះថ្មភ្នំ ការកាយជញ្ជាំងភ្នំ និងការចាក់សំណល់ដី ថ្ម ចោលដោយមិនបានបង្ហាប់ និងដាំស្មៅជាដើម ។ ម្យ៉ាងទៀតអាច មានការបំពុលគុណភាពទឹកពីកន្លែងលាងថ្ម ខ្សាច់ដើម្បីលាយបេតុងរួចទឹកហូរចូលអូរ ស្ទឹង ព្រែក ដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតសត្វ និងមនុស្ស ដែលប្រើប្រាស់ទឹកនេះ ។

ម្យ៉ាងទៀតអាចនឹង ប៉ះពាល់គុណភាពទឹកស្ទឹងដោយសារកាកសំណល់រឹង-រាវ មកពីការបោះចោលកាកសំណល់ផ្ទះបាយ បង្គន់ ដែលសង់គ្មានបច្ចេកទេស និងការខ្វះខាតបង្គន់អនាម័យគ្រប់គ្រាន់ សម្រាប់បុគ្គលិកកម្មករគំរោង និងការបោះកាកសំណល់សំភារៈសំណង់ ដោយបុគ្គលិក កម្មករក្រុមហ៊ុន (ការហៀរ ឬលេចជាតិប្រេងពីគ្រឿងចក្ររថយន្ត បារ៉ស៊ីម៉ង់ត៍បារ៉ ឬស្បោងប្រកសារធាតុគីមីផ្សេងទៀត ។ល។) ។

បន្ថែមពីលើនេះទៀត អាចនឹងមានការហូរច្រោះដី ដោយសារការកាប់ឆ្ការនូវគំរបរុក្ខជាតិ ដូចជាការកាប់ព្រៃ ការឈូសឆាយដីធ្វើហេដ្ឋារចនាសម្ព័ន្ធគំរោង និងការកាប់រានព្រៃឈើនៅតាមដងអូរ ឬស្ទឹង ដែលនឹងត្រូវលិចជាដើម ។

  - **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងមិនឈូសឆាយទ្រង់ទ្រាយធំនៅរដូវវស្សាទេ ។

ដើម្បីការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ក្រុមហ៊ុននឹងធ្វើរបាំងការពារ ។ ម្យ៉ាងវិញទៀតនៅកន្លែងលាងថ្ម និងលាយបេតុងក្រុមហ៊ុននឹងធ្វើប្រព័ន្ធកាត់បន្ថយភាពល្អក់ដោយជីកប្រឡាយជុំវិញរួចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ ទំហំ១០x១០x៣ម. (បណ្តោយxទទឹងxជំរៅ) បន្ទាប់មកទឹកនេះហូរចូលអាងរងកករទី២មានទំហំ ១០x១៥x៣ម (បណ្តោយ xទទឹងxជំរៅ) ។

ក្រុមហ៊ុននឹងធ្វើការអប់រំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពី អនាម័យស្គាល់នូវកន្លែងទុកដាក់សំរាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង ។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រាវ ដោយសាងសង់បង្គន់អនាម័យបន្ទប់ទឹកឱ្យឆ្ងាយពីមាត់ស្ទឹងដោយមាន អាងសិបទិកត្រឹមត្រូវព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពល្អមិនឱ្យប៉ះពាល់បរិស្ថានជុំវិញមិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬព្រែកឡើយ ដោយមានកន្លែងទុកដាក់សំណល់រឹងល្អតាមបច្ចេកទេស ។

ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងកាកសំណល់រឹង នោះក្រុមហ៊ុននឹងបោះផ្លាកសញ្ញានៅក្នុង និងក្បែរតំបន់គំរោងដោយមានអក្សរខ្មែរ និងចិនអំពីការបំពុលទឹក ។

សាងសង់អាងសិបទិកតាមបច្ចេកទេសសម្រាប់ទឹកកខ្វក់ចេញពីការិយាល័យបន្ទប់ទឹក បង្គន់ ផ្ទះបុគ្គលិក ដែលស្នាក់នៅបណ្តោះអាសន្នក្នុងពេលសាងសង់គំរោង ។

សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋាន សុវត្ថិភាព ដល់បរិស្ថាន និងសង្គម ។

ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មក លើដី និងប្រភពទឹកក្នុងតំបន់គំរោង។

ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក នោះក្រុមហ៊ុននឹងដាំព្រៃឈើឡើងវិញនៅតាមកន្លែងចាក់ចោលដីស្អុយ ឬសំណល់ថ្ម កន្លែងយកដី និងថ្ម។ ជាងនេះទៅទៀត ក្រុមហ៊ុនបានបាញ់ស៊ីម៉ង់ត៍ ៣សនៅកន្លែងជញ្ជាំងភ្នំដែលសំខាន់ៗ ដូចជាៈ នៅក្បែរទំនប់ នៅអគាថាមពល...។ល។ ដើម្បីការពារការហូរច្រោះ និងរអិលបាក់ជញ្ជាំងភ្នំ ធ្វើឱ្យបំពុលទឹកកំឡុងពេលសាងសង។

ធ្វើការដាំស្មៅនៅជញ្ជាំងភ្នំ និងនៅជញ្ជាំងកន្លែងចាក់សំណល់ដី និងថ្ម ដែលខ្លួនបានធ្វើ។

គ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬព្រែកឡើយ ដូចជា សង់បន្ទប់ទឹក និងបង្គន់អនាម័យឆ្ងាយពីស្ទឹងមានអាងសិបទិក ត្រឹមត្រូវមានកន្លែងទុកដាក់សំណល់រឹងល្អតាមបច្ចេកទេស។

ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យ ដោយជីករណ្តៅដាក់លូដើម្បីស្តុកលាមកមានជំរៅពី ២,៥ ទៅ ៣,៥ ម ដើម្បីសំលាប់មេរោគ ។ ចំពោះ សំណល់ផ្ទះបាយវិញ គឺមិនបង្ហូរ ឬចាក់ចូលទៅក្នុងស្ទឹងកំចាយទេគឺជីករណ្តៅ ជំរៅ១-២ ម. ទំហំ ៤ ទៅ ៦ម២ ដើម្បីធ្វើឱ្យកាកសំណល់នោះក្លាយ ជាជីកំប៉ុស៍បានថែមទាំងមានធុងទុកសម្រាប់ដាក់សំរាម និងកន្លែងដុតសំរាមចោលដោយសុវត្ថិភាព។

- **ការបំពុលដី**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងនេះ អាចនឹងមានការបំពុលដីដោយសារការកំពប់នៃប្រេងឥន្ធនៈ ការកំពប់នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដី ដូចជាៈ កាកសំណល់ចេញពី ឬលេចធ្លាយពីគ្រឿងចក្រ និងរថយន្តគ្រប់ ប្រភេទ ដែលដំណើរការគំរោងនេះ ព្រមទាំងកាកសំណល់ចេញពីផ្ទះបាយ។

ដោយសារការចាក់ដីស្អុយ ឬសំណល់ថ្ម ដែលជីកចេញពីតំបន់គំរោងនោះ ក៏អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់ស្រទាប់ដីខាងលើផងដែរ។

អាចនឹងមានការបំពុលដីដោយសារ ការគ្រប់គ្រងនូវសារធាតុផ្ទុះមិនបានល្អធ្វើឱ្យធ្លាក់ទៅលើដី។ ការឈូសឆាយព្រៃស្រទាប់លើនៅតាមតំបន់ទីជំរាលធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សា និងមានសំណឹក ដោយសារខ្យល់នៅរដូវប្រាំងក៏បានធ្វើដីបាត់បង់គុណភាពផងដែរ។

ដោយសារតែតម្រូវការស៊ីម៉ង់ត៍ច្រើនក្នុងការសាងសង់នោះសំបកបាវរបស់វានឹងអាចរាយប៉ាយលើដីដែលធ្វើឱ្យមានការបំពុលដី នៅការដ្ឋាន និងផ្នែកខាងក្រោម។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវមិនឱ្យកំពប់ ឬជ្រាបចូលដីឡើយ។

ក្រុមហ៊ុននឹងពង្រាបដី ឬថ្មដែលចាក់ចោលដោយយកដីមានជីជាតិលប់ ពីលើរួចដាំដើមឈើឡើងវិញក្នុងតំបន់នេះដោយធ្វើការសហការជាមួយក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ។

ក្រុមហ៊ុននឹងគ្រប់គ្រងកាកសំណល់រឹងរាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវ ដូចជាៈ ចាត់វិធានការយ៉ាងតឹងរ៉ឹងមិនឱ្យចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោលទៅលើដី ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងធ្វើការដាក់ទ័ណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តខុស ដូចជាៈ ស្តីបន្ទោស ពិន័យ ឬការបណ្តេញពីការងារជាដើម ។

ចំពោះសំបកបារ៉ស៊ីម៉ង់ត៍ ដែលក្រុមហ៊ុននឹងរក្សាទុកដោយមានរបៀប នៅឯឃ្លាំងសំភារៈដើម្បីប្រើឡើងវិញ ។ ជាងនេះទៅទៀត ក្រុមហ៊ុនមានអ្នកទទួលខុសត្រូវលើការរក្សាទុកសំភារៈប្រើប្រាស់ដែលនៅសល់ពីការងារ ដើម្បីយកទៅរក្សាទុកយ៉ាងត្រឹមត្រូវ ។

- **សំលេង និងរំញ័រ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋដែលចេញចូលទីនោះ និងពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគំរោងដោយសារមានសំលេង និងរំញ័រចេញពីគ្រឿងចក្រ រថយន្ត ម៉ាស៊ីនគ្រប់ប្រភេទពេលកំពុងធ្វើការងារ ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំៗ ។ល។

អាចមានការប៉ះពាល់ដោយសារសំលេងពីភាពខ្សៀវខ្សាររអឹងកងពី បុគ្គលិកកម្មករគំរោង ដែលមានជាមធ្យមប្រមាណ ២២៣៦ នាក់ ធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគំរោងនោះផង ដែរ ។

ការប្រើប្រាស់ម៉ាស៊ីនភ្លើងសម្រាប់បម្រើឱ្យការសាងសង់អាចធ្វើឱ្យ មានការបំពុលដោយសំលេង និងរំញ័រដែលធ្វើមានការរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងពពួកសត្វព្រៃមួយចំនួនក្នុងតំបន់គំរោង ។ ការរញ្ជួយដោយសារការដឹកសម្ភារៈសំណង់ធ្ងន់ៗ (ថ្ម ខ្សាច់ ប្រើគ្រឿងរំញ័រក្នុងការបង្ហាប់បេតុង និងដឹកដុំទូរប៊ីនភ្លើង) ក្នុងការសាងសង់ទំនប់សាងសង់រន្ធទូនេលអគារថាមពល ការដឹកសម្ភារៈបង្គោលភ្លើងជាដើម ។

  - **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូន ដែលមានសំលេងតិច ។

ក្រុមហ៊ុននឹងកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់ រួចដាក់ផ្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះដើម្បីឱ្យកម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់ ។ ជាងនេះទៅទៀត ក្រុមហ៊ុនបានជួលដីនៅជុំវិញកន្លែងបំផ្ទុះយកថ្ម ១០០ ម. ដោយតម្លៃ៥០០០ ដុល្លារ/ហ.ត សម្រាប់មួយរយៈពេលនៃការបំផ្ទុះយកថ្មនេះ ។

ក្រុមហ៊ុននឹងកំណត់កម្រិតរញ្ជួយ និងកំលាំងបំផ្ទុះឱ្យតូចដែលមិនប៉ះពាល់ ដល់ការបាក់ផ្ទែកខ្លះនៃភ្នំ ឬផ្លូវដែលនៅក្បែរតំបន់បំផ្ទុះ ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងផ្តល់ព័តិមាន និងផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋដែលចេញចូលទីនោះ ។

ចំពោះការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល (ម៉ោង ៤:០០-៥:០០ ល្ងាច) ។

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខានដល់ប្រជាពលរដ្ឋ និងសត្វព្រៃក្នុងតំបន់គំរោងនេះ ។

Draft

ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកកម្មករគំរោងឱ្យចេះស្ងៀមស្ងាត់ នៅពេលម៉ោងសំរាក និងនៅពេលយប់។

ក្រុមហ៊ុននឹងដំឡើងទួរប៊ីនកំលាំង ១០ MW ជាមុន ដើម្បីបម្រើការសាងសង់នេះជំនួសម៉ាស៊ីនភ្លើង។ ប៉ុន្តែនៅរយៈពេល៤ ឬ៥ខែដំបូង ក្រុមហ៊ុននឹងប្រើប្រាស់ចរន្តអគ្គិសនីពីខេត្តកំពត។

រាល់សំភារៈសំណង់ធន់ធ្ងន់ក្រុមហ៊ុន និងធ្វើការដោះបំបែក និងផ្ទេរចែករំលែកឱ្យងាយក្នុងការដឹកជញ្ជូនវា ទោះបីត្រូវប្រើរថយន្តដឹកច្រើនជើងក៏ដោយ ។ ក្រុមហ៊ុន ក៏នឹងប្រើប្រាស់រថយន្តមានកងច្រើនដើម្បីកាត់បន្ថយរំញ័រក្នុងការដឹកសម្ភារៈធ្ងន់ៗ។

## ១. ធនធានជីវសាស្ត្រ

- **ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់ហេដ្ឋារចនាសម្ព័ន្ធនេះអាចប៉ះពាល់ដល់ផ្លូវចេញចូលរបស់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារក្រុមហ៊ុនទប់ទំនប់បណ្តោះអាសន្នកាត់ស្ទឹងកំចាយដើម្បីសាងសង់ទំនប់វារីអគ្គិសនីនេះ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនគ្មានគំរោងសាងសង់ជណ្តើរត្រីទេ។

បន្ថែមពីលើនេះទៅទៀតវាក៏អាចប៉ះពាល់គុណភាពទឹកស្ទឹងកំចាយ ធ្វើឱ្យបំពុលដល់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារការធ្វើឱ្យល្អក់ទឹក បណ្តាលមកពីសកម្មភាពសាងសង់គំរោង កន្លែងលាងថ្ម និងបំពុលទឹកដោយសារកាកសំណល់រឹង-រាវ ចេញពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង។

ឆ្លងតាមការចុះសិក្សាផ្ទាល់ ដោយប្រើឧបករណ៍ចាប់ត្រីរបស់ក្រុម ការងារជលផលបានឱ្យដឹងថា នៅក្នុងទំនប់មានត្រីចំនួន១៥ ប្រភេទ និងក្រោមទំនប់មាន១៧ប្រភេទដែលជាត្រីទឹកសាបនៅក្នុងស្ទឹងកំចាយ ហើយក្រុមការងារក៏បានរកឃើញពពួកត្រីទឹកភ្លាវចំនួន២៦ប្រភេទទៀត ដែលរស់ក្នុងព្រែកកំចាយនេះ និងមានប្រភពមកពីតំបន់ឆ្នេរ។ ការបិទទ្វារទឹកដើម្បីតំកល់ទឹកក្នុងអាងអាចប៉ះពាល់ដល់ប្រភេទវារី សត្វងាយរងគ្រោះថ្នាក់មួយចំនួន។ ដោយសារពួកវាមិនអាចឆ្លង កាត់ទំនប់ចុះឡើងបាន។ ក៏ប៉ុន្តែការបង្កើតអាងទឹកដ៏ធំអាចមាន ការកើន ឡើងនៃវារីសត្វផងដែរ ដូចជាសុភាសិតខ្មែរពោលថា ទីណាមានទឹក គឺទីនោះមានត្រី។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋានទំនប់ ដែលមានសណ្ឋានដូចផ្លូវទឹកចាស់ (មិនចោទ) ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើចរាចរ នៃជីវសាស្ត្រក្នុងទឹកពីផ្នែកខាងក្រោមការដ្ឋានទៅផ្នែកខាងលើការដ្ឋាន។ ម្យ៉ាងវិញទៀតនៅកន្លែងលាងថ្មលាយបេតុងក្រុមហ៊ុននឹងធ្វើប្រពន្ធ័កាត់បន្ថយភាពល្អក់ ដោយជីកប្រឡាយជុំវិញរួចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ទំហំ១០x១០x៣ម.(បណ្តោយxទទឹងxជំរៅ) បន្ទាប់មកទឹកនេះហូរចូលអាងរងកករទី២ មានទំហំ១០x១៥x៣ម (បណ្តោយxទទឹងxជំរៅ)។

ធ្វើការដាំស្មៅ ឬរៀបថ្មដាក់សំណាញ់ដែកដោយបាញ់ស៊ីម៉ង់ត៍ពីលើនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោទផ្សេងៗដើម្បីធ្វើផ្លូវធ្វើទំនប់ និងធ្វើហេដ្ឋារចនាគំរោង ដទៃទៀតដើម្បីការពារការហូរច្រោះបាក់ជញ្ជាំងភ្នំបន្ថែម និងការពារភាពល្អក់ខ្លាំងហូរចូលស្ទឹង។

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាប្លង់គំរោងដោយរួមបញ្ចូលនូវសំណង់សិល្បៈការសម្រាប់ឱ្យត្រីឆ្លងកាត់បាន បើមានការសិក្សារកឃើញថាមាន ប្រភេទត្រីមានប្រយោជន៍ដល់សេដ្ឋកិច្ចជាច្រើនប្រភេទមានបំលាស់ទី ក្នុងការបន្តពូជពីខ្សែទឹកខាងក្រោមទៅខ្សែទឹកលើ ឬពីខ្សែទឹកខាងលើមកខ្សែទឹកខាងក្រោមវិញ នៃស្ទឹងកំចាយព្រមទាំងមានការស្នើសុំពីរាជរដ្ឋាភិបាល និងអ្នកឯកទេសជលផលជាតិ ។

ក៏ប៉ុន្តែក្រុមហ៊ុននឹងមានវិធានការដើម្បីជំនួសសំណង់សិល្បៈការសម្រាប់ឱ្យត្រីឆ្លងកាត់នេះ ដោយរៀបចំកម្មវិធីព្រលែងត្រីក្នុងអាងដោយសាងសង់ស្ថានីយ៍សម្រាប់បង្កាត់ពូជត្រីដែលមាននៅក្នុងគំរោង ។ (**<u>សម្គាល់:</u>** ចំពោះតម្លៃនៃសំណង់សម្រាប់ត្រីឆ្លងកាត់បានមានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ ។

អប់រំដល់បុគ្គលិកកម្មករអំពីការបោះបង់កាកសំណល់រឹង-រាវជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅលើដី និងក្នុងទឹកនៅក្នុងតំបន់គំរោង ។ រីឯសារធាតុគីមីដែលត្រូវយកមកប្រើសម្រាប់ការលាយបេតុង វិញក្រុមហ៊ុនមានអ្នកបច្ចេកទេសទទួលខុសត្រូវក្នុងការគ្រប់រគងយ៉ាងត្រឹមត្រូវ ។ ក្រុមហ៊ុននឹងគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទនៅទីតាំងដែលមានសុវត្ថិភាព ។

- **ធនធានព្រៃឈើ និងជីវកសត្វព្រៃ**

  - ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

អាចនឹងប៉ះពាល់ដល់ផ្ទៃដីព្រៃឈើសរុប ១៩៦១,៩៦ ហ.ត ក្នុងនោះមានព្រៃស្រោង ១៥៤៥,៩៦ ហ.ត និងព្រៃល្បាយឬស្សី ៤១៦ ហ.ត ។ ព្រៃឈើដែលត្រូវលិច ១៧៨៨ ហ.ត ក្នុងនោះមានព្រៃស្រោង ១៣៧២ ហ.ត (១៣៩ ប្រភេទ) និងព្រៃល្បាយឬស្សី ៤១៦ ហ.ត (៦០ប្រភេទ) ។ ព្រៃឈើទាំងនេះជាជីវកសត្វព្រៃក្នុង តំបន់ជាច្រើនប្រភេទដូចមានចែងក្នុងជំពូក៥ ចំណុច៥.២.៦.៣នេះ ដែលជាការព្រួយបារម្ភ និងសោកស្តាយរបស់ប្រជាជន និងរាជរដ្ឋាភិបាលចំពោះសម្បត្តិធនធានធម្មជាតិរបស់កម្ពុជា ។ (ដោយមិនរួមទាំងខ្សែបញ្ជូនចរន្ត២៣០ kV) (រីឯខ្សែបញ្ជូនចរន្តវិញមាននៅជំពូក៨ )

ម្យ៉ាងវិញទៀតអាចនឹងមានការទន្ទ្រានចាប់ដីធ្វើកម្មសិទ្ធិពីសំណាក់ជនឆ្លៀតឱកាសមួយចំនួន ក្នុងឧទ្យានជាតិព្រះមុនីវង្សនៃក្រសួងបរិស្ថាន ដោយសារមានការអភិវឌ្ឍវារីអគ្គិសនីនៅតំបន់នេះ ។

បន្ថែមពីលើនេះ អាចមានការទន្ទ្រានចូលព្រៃការពារក្បែរតំបន់គំរោង ដើម្បីរកកាប់ឈើប្រណិត (ក្រញូង បេងជាដើម) ពីសំណាក់ជនឆ្លៀតឱកាស តាមមធ្យោបាយគ្រប់រូបភាព ពីព្រោះអាងតែខ្លួន ទទួលបាននូវអាជ្ញាបណ្ណនាំឈើចេញក្រៅតំបន់នេះពីរាជរដ្ឋាភិបាលក្នុងការសំអាតដីព្រៃឈើដែលនឹងត្រូវលិចក្នុងតំបន់ ១៧៨៨ហ.ត និងនៅតំបន់សាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង [redacted].ត ហ.ត ។

អាចនឹងកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គំរោង ដោយសារបុគ្គលិក-កម្មករគំរោង ។

  - ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានបង្ហាញនៅក្នុងប្លង់រចនាគំរោងលម្អិតឡើយ ។ ម្យ៉ាងទៀត ក្រុមហ៊ុនមិនធ្វើការសំអាតព្រៃនៅតំបន់នេះចំនួន១៩៦១,៩៦ហ.ត ទាំងស្រុងនោះទេពោលគឺ សំអាតនៅកន្លែងដែលសាងសង់សំណង់ជាក់ស្តែងប៉ុណ្ណោះ (ចំពោះកន្លែងដែលនឹងត្រូវសាងសង់ទាំងនេះនឹងធ្វើលម្អិតនៅក្នុងដំណាក់កាលគ្រោងលម្អិតរបស់គំរោង) ។

Draft

រីឯ ខ្សែបញ្ជូនចរន្ត២៣០ kV ១១,០៥ គ.ម វិញគឺសាងសង់កាត់តាមចង្កេះភ្នំ ចំការ និងដីស្រែរបស់ប្រជាពលរដ្ឋ (ទោះបីខ្សែនេះ ៤,៨៣ គ.ម ស្ថិតនៅក្នុងតំបន់ការពារនៃឧទ្យានជាតិក៏ដោយ គឺមិនមានព្រៃឈើធំដុំគួរឱ្យកត់សម្គាល់ឡើយ) ។

ក្រុមហ៊ុននឹងធ្វើការប្រឹក្សាជាមួយឧទ្យានជាតិព្រះមុនីវង្សនៃក្រសួងបរិស្ថាន និងអង្គការនានាដែលពាក់ព័ន្ធរកទីតាំងសមស្របក្នុងតំបន់ក្បែរព្រៃ ដែលបាត់បង់ដោយសារសកម្មភាពគំរោងសម្រាប់ដាំឈើទុកជាជំរកដល់សត្វព្រៃផង និងដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថានក្នុងតំបន់នេះ ។

ការសហការជាមួយក្រសួងបរិស្ថាននឹងធ្វើឡើង ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលអាចកើតមានជាយថាហេតុលើព្រៃឈើដែលនៅជាប់នឹងតំបន់គំរោងក្នុងដំណាក់កាលនៃការសាងសង់នេះ ។

ក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីធ្វើការសំអាតព្រៃក្នុងតំបន់ ដែលនឹងត្រូវលិចតំបន់ហេដ្ឋារចនាសម្ព័ន្ធ និងអគារថាមពល ដូចជាក្រសួងអាចលក់ឈើឱ្យក្រុមហ៊ុនផ្សេងទៀត ដែលក្រុមហ៊ុននេះត្រូវកែច្នៃឈើទាំងនោះឱ្យអស់លទ្ធភាព ដែលអាចធ្វើទៅបាន ហើយបានថវិកាចូលរដ្ឋថែមទៀតផង ។ ម្យ៉ាងទៀត នៅក្នុងតំបន់សាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោងក្រុមហ៊ុនមិនធ្វើការឈូសឆាយកាប់ព្រៃឈើទាំង ១៩៦១,៩៦ហ.ត នោះទេ គឺខិតខំព្យាយាមរក្សាទុកតំបន់ព្រៃស្រោងមួយចំនួន ។

ក្រុមហ៊ុននឹងសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអង្គការសហប្រតិបត្តិការណ៏ ក្នុងការទប់ស្កាត់ ការរានដីយកធ្វើកម្មសិទ្ធិខុសច្បាប់ដោយបង្កើនកំលាំងការពារ និងត្រួតពិនិត្យឱ្យបានម៉ត់ចត់ ។

ជាងនេះទៅទៀតក្រុមហ៊ុននឹងដាក់ផ្លាកសញ្ញាតំបន់ការពារ និង ហាមបរបាញ់ជាអក្សរភាសាខ្មែរ និងចិនឱ្យបានច្រើនដើម្បីឱ្យប្រជាពលរដ្ឋ និងចិនងាយមើលឃើញ ។

ក្រុមហ៊ុននឹងបំពាក់នូវឧបករណ៏សំភារៈសម្រាប់ពន្លត់អគ្គិភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៏ដែលឱ្យសញ្ញាពេលមានអគ្គិភ័យកើតមានឡើង ។

- **ជីវសាស្ត្រ សត្វព្រៃ**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការបាត់បង់ជំរកព្រៃមួយចំនួនក្នុងតំបន់អាងស្តុកទឹករបស់វារីអគ្គិសនីនេះនឹងធ្វើឱ្យមានការថយចុះសត្វព្រៃមួយចំនួននៅក្នុងតំបន់គំរោង ។

ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់ បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និងថែទាំគំរោង ក៏បណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃក្នុងតំបន់នេះផងដែរ ដូចជាថយចុះចំនួន និងបាត់បង់ពូជសត្វដែលកំពុងការពារដោយក្រុមការងារឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) នៃក្រសួងបរិស្ថាន ។ [redacted]

ការអនុវត្តនៅតំបន់នេះអាចធ្វើឱ្យមានការហូរចូលជនចំណូលថ្មីមកពីតំបន់ផ្សេងៗដើម្បីទន្ទ្រានកាន់កាប់ដី និងរស់នៅទីនោះធ្វើឱ្យបាត់បង់ធនធានធម្មជាតិដែលជាទីជំរកសម្រាប់បន្តពូជ និងរកចំណីរបស់សត្វក្នុងតំបន់ទាំងនោះ ។

សកម្មភាពកាប់ឆ្ការគំរបព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសំភារៈសាងសង់ នឹងនាំឱ្យមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះ ដោយសារមានសំលេងរំខានខ្លាំងៗចេញពីម៉ាស៊ីន គ្រឿងយន្តគ្រឿងផ្ទុះ និងសំលេងខ្សៀវខ្សាររបស់បុគ្គលិក-កម្មករគំរោង ។

Draft

ការជ្រើសរើសនូវបុគ្គលិកកម្មករជាមធ្យម ២២៣៦នាក់ ចូលមកធ្វើការនៅតំបន់នេះសម្រាប់ការសាងសង់គំរោង នឹងអាចមានសកម្មភាពបរបាញ់ ឬចាប់សត្វ ឬចូលព្រៃពីសំណាក់បុគ្គលិក-កម្មករគំរោងទាំងនោះធ្វើឱ្យផ្អើល និងបាត់បង់សត្វព្រៃទៀតផង។

ការជួញដូរសត្វព្រៃនៅតំបន់គំរោងអាចមានការកើនឡើង ដូចជា ការយកធ្វើម្ហូប ការធ្វើថ្នាំបុរាណជាដើម ។ល។ ធ្វើឱ្យហិនហោចបាត់បង់សត្វព្រៃពីតំបន់ការពារទាំងនេះ ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងហាមឃាត់ដល់បុគ្គលិកកម្មកររបស់គំរោងមិនឱ្យទន្ទ្រាន កាន់កាប់ដី ឬរុករានព្រៃ និងបំផ្លាញជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង។

ក្រុមហ៊ុននឹងបញ្ជាឱ្យក្រុមការងារតាមផ្នែករបស់ខ្លួនធ្វើការអប់រំ និងហាមឃាត់ដល់បុគ្គលិក-កម្មករ តាមផ្នែក ឬក្រុមរបស់ខ្លួនមិនឱ្យទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃ្មុំ ដែលអាចបង្កការឆេះព្រៃឈើ ។

ក្រុមហ៊ុននឹងដាក់ពិន័យដល់បុគ្គលិកកម្មករណាដែលប្រព្រឹត្តល្មើសនឹងការហាមឃាត់ខាងលើ។

ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលអាចនឹងកើតឡើងជាយថាហេតុនៅក្នុងតំបន់គំរោងនោះ ក្រុមហ៊ុននឹងធ្វើការសហការជាមួយក្រសួងបរិស្ថាន និងក្រុមការងារឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) ដើម្បីដោះស្រាយ។

ដោយឡែកចំពោះកិច្ចការពារអគ្គិសភ័យ ក្រុមហ៊ុននឹងបំពាក់នូវឧបករណ៍សំភារៈសម្រាប់ពន្លត់អគ្គិភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ដែលឱ្យសញ្ញាពេលមានអគ្គិភ័យកើតមានឡើង ។

ជាបន្ថែម ក្រុមហ៊ុននឹងត្រៀមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារឡើងវិញនូវជំរកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជា ការដាំឈើឡើងវិញនៅតំបន់ដែលគ្មានឈើដុះក្បែរនោះដោយធ្វើការជាមួយក្រសួងបរិស្ថាន និងក្រុមការងារឧទ្យានជាតិព្រះមុនីវង្ស (បូកគោ)។

ក្រុមហ៊ុននឹងត្រៀមមូលនិធិបំរុងសម្រាប់ការការពារបរិស្ថាន ដូចជា: ការដាំឈើធ្វើទីជំរកសត្វឡើងវិញ បង្កើនកំលាំងការពារទប់ស្កាត់ និងថែរក្សាសត្វព្រៃ ដោយសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន។

បង្កើតស្ថានីយ៍ចិញ្ចឹមត្រី និងសង្គ្រោះសត្វព្រៃ រួចយកវាទៅលែងនៅតាមអូរ ស្ទឹង ធម្មជាតិដែលនៅក្បែរតំបន់គំរោង ដោយមានការសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន។

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ជិតគំរោង ។

ការកំណត់កម្រិតរញ្ជួយ និងកំលាំងបំផ្ទុះ និងប្រើប្រាស់ម៉ាស៊ីន ដែលមានសំលេង និងរំញ័រតិចនឹងត្រូវអនុវត្តន៍ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនេះ។

បន្ថែមពីលើនេះ ក្រុមហ៊ុននឹងអប់រំ និងដាក់វិន័យដល់បុគ្គលិក-កម្មករ គំរោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ ។ ព្រមទាំងដាក់ផ្លាកសញ្ញាតំបន់ការពារ និងហាមបរបាញ់ជាអក្សរភាសាខ្មែរ និងចិនឱ្យបានច្រើនដើម្បីឱ្យប្រជាពលរដ្ឋ និងចិនងាយមើលឃើញ។

Draft

ក្រុមហ៊ុននឹងចូលរួមសហការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការសហប្រតិបត្តិការណ៍នៅតំបន់នេះ ដើម្បីទប់ស្កាត់បទល្មើសសត្វព្រៃ និងព្រៃឈើ ។

- **តំបន់ឧទ្យានជាតិព្រះមុនីវង្ស (បូកគោ)**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ផ្ទៃដីសរុបរបស់គំរោងគឺ២.២៩១,៣៧ហ.ត.ក្នុងនោះមាន ២.០១៥,៧ ហ.ត ជាអាងទឹកទាំងពីរ (ព្រមទាំងទំនប់ទាំងពីរ) ហេដ្ឋារចនាសម្ព័ន្ធគំរោងមាន ២៣៨,៩៦ ហ.ត (អគារថាមពល ផ្លូវ ទំនប់ និងតំបន់ហេដ្ឋារចនាសម្ព័ន្ធនានារបស់គំរោង) ហើយក្នុងនោះមានការប៉ះពាល់ដល់ តំបន់ឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) របស់ក្រសួងបរិស្ថានចំនួន ២.២២៩,៧៧ ហ.ត. (ក្នុងនោះព្រៃស្រោង ១៩៤៥,៩៦ ហ.ត និងព្រៃល្បាយឫស្សី ៤១៦ ហ.ត) ។

ការបំពុលបរិស្ថាននៅក្នុងតំបន់អភិរក្សនេះ [redacted] ការបំពុលខ្យល់ បំពុលទឹក ដោយសារសំណល់បញ្ចេញចោល ពីកន្លែងសាងសង់ និងចេញពីកន្លែងស្នាក់នៅរបស់កម្មករ បុគ្គលិក កន្លែងស្តុកគ្រឿង និងសំភារៈ សំណង់ និងពីគ្រឿងចក្រដូចបានរៀបរាប់ខាងលើ ។

អាចមានការទន្ទ្រានចូលក្នុងព្រៃនៃតំបន់កាពារទាំងនេះពីសំណាក់ក្រុមកម្មករ ក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬការទិញលក់ ចរាចរឈើ និងសត្វព្រៃជាដើម ។

អាចនឹងមានការទន្ទ្រានកាន់កាប់យកដីព្រៃការពារ ដីតំបន់អភិរក្សទាំងនេះពីសំណាក់ជនឆ្លៀតឱកាសដោយសារគំរោងធ្វើផ្លូវគន្លងខ្សែចម្លង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគំរោង ។

អាចនឹងកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គំរោង ដោយសារបុគ្គលិក-កម្មករគំរោង ។

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងត្រៀមមូលនិធិបំរុងសម្រាប់ការការពារបរិស្ថាន ដូចជា: ការដាំឈើបង្កើនការទប់ស្កាត់ការពារ និងថែរក្សាសត្វព្រៃក្នុងតំបន់ដោយសហការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការសហប្រតិបត្តិការនានា ។

កំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្កសំលេង និងរំញ័រដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ក្បែរខាង ។

ក្រុមហ៊ុននឹងកំណត់កម្រិតរញ្ជួយ និងកំលាំងបំផ្ទុះ និងប្រើប្រាស់ម៉ាស៊ីន ដែលមានសំលេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃ ។

ក្រុមហ៊ុននឹងសាងសង់បង្គន់អានាម័យ និងបន្ទប់ទឹកសម្រាប់អ្នកធ្វើការទាំងអស់នៅក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់គំរោង ។ រៀបចំការគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវមានសុវត្ថិភាព ជាពិសេសមិនឱ្យបំពុលបរិស្ថានក្នុងតំបន់អភិរក្សទាំងនោះ ។

ក្រុមហ៊ុននឹងធ្វើការអប់រំ និងដាក់វិន័យដល់កម្មករគំរោងមិនឱ្យធ្វើការទន្ទ្រានព្រៃក្នុងតំបន់អភិរក្សទាំងនោះ ដើម្បីចាប់ ឬបរបាញ់ចរាចរឈើ និងសត្វព្រៃដោយសហការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការសហប្រតិបត្តិការ ។ ដោយដាក់ផ្លាកសញ្ញាព្រៃការពារ និងហាមបបាញ់ជាអក្សរខ្មែរ និងចិនឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងចិនងាយមើលឃើញ ។

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដទៃទៀតដើម្បីការពារ និងទប់ស្កាត់កុំឱ្យមានការរំលោភ កាន់កាប់ដីនៅតំបន់អភិរក្សទាំងនោះ បន្ទាប់ពីឃើញមានសកម្មភាពសាងសង់គំរោង (តំបន់គំរោងស្ថិតនៅក្នុងតំបន់

Draft

ឧទ្យានជាតិប្រមាណជា ២២៣០.៣៨ ហ.ត ក្នុងនោះមានខ្សែបញ្ជូនចរន្ត ១៤,៤៩ ហ.ត ដែលមានប្រវែង ៤,៨៣ គ.ម)។ (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត និងជំពូក៥)

**គ. ធនធានសេដ្ឋកិច្ចសង្គម**

- **ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

អាចនឹងប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋដែល រស់នៅក្នុងទីតាំងហេដ្ឋារចនាសម្ព័ន្ធគំរោង (ទំនប់ទី២ អាងស្តុកទឹកទី២ សំណង់សិល្បៈការណ៍ផ្សេងៗ ៧.៨៥ ហ.ត ដែលជាដីចំការ ដោយមិនរួមបញ្ចូលផ្លូវដឹកសំភារៈ ៤,៧២ ហ.ត (ផ្លូវគ្រួសក្រហម៥,៩ គ.ម x ៨ ម. ពីប៉ុស្តិ៍យាមផ្នែកខាងឆ្វេងនៃដៅទឹកហូរដល់ស្ពានដែក) រីឯទំនប់ទី១ និងអាងទឹកទី១វិញ គឺស្ថិតនៅក្នុងព្រៃនៃតំបន់ការពារមិនមានដីរបស់ប្រជាពលរដ្ឋឡើយ។ (មិនគិតពីខ្សែ ២៣០គ.វ៉ុល)។

ចំពោះខ្សែចំលង ២៣០kV វិញមានប្រវែងសរុប១១,០៥គ.ម. ត្រូវនឹង ៣៣,១៥ហ.ត (១១,០៥គ.មx៣០ម.) ដែលកាត់តាមតំបន់ឧទ្យានជាតិ៤,៨៣ គ.មស្មើនឹង ១៤,៤៩ហ.ត (៤,៨៣គ.ម. x ៣០ម.)។ មានដីប្រើប្រាស់របស់ប្រជាពលរដ្ឋនៅតាមគន្លងខ្សែបញ្ជូនចរន្ត ២៣០ kV ទាំង ៣៤ បង្គោលចំនួន ៣១,៦៩ ហ.ត ក្នុងនោះមាន ០,៤៩ ហ.ត ជាដីប្រើប្រាស់របស់ប្រជាពលរដ្ឋដែលនឹងប៉ះពាល់ដោយបង្គោលភ្លើង។

មានប្រជាពលរដ្ឋដែលមានលំនៅដ្ឋានក្បែរកន្លែងយកថ្ម ១៥គ្រួសារ នឹងអាចប្រឈមទៅនឹងគ្រោះថ្នាក់នៅពេលបំផ្ទុះថ្ម (ដុំបជ្រីង និងដុំបមាន់ព្រៃ) ក្នុងភូមិទ្វារថ្មី ឃុំព្រៃថ្នង ស្រុកទឹកឈូរ ខេត្តកំពតអាចធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពកម្មករ និងប្រជាពលរដ្ឋដែលរស់នៅជុំវិញ។ ជាងនេះទៅទៀត ការឈូសឆាយទីតាំងយកថ្ម (ដុំបជ្រីង និងដុំបមាន់ព្រៃ) ដើម្បីកិនបំបែក សម្រាប់ដឹកជញ្ជូនធ្វើឱ្យប៉ះពាល់ដល់ដំណាំ និងដីចំការរបស់ប្រជាពលរដ្ឋ។

ការដឹកជញ្ជូនថ្មពីការដ្ឋានយកថ្មមកដល់កន្លែងលាយបេតុងមានចំងាយឆ្ងាយ ត្រូវកាត់តាមផ្លូវជាតិលេខ ៣ បណ្តាលឱ្យខូច និងស្រុតផ្លូវដែលមានស្រាប់នេះ។

មាន ១៦ ខ្នងផ្ទះ ដែលស្ថិតនៅក្រោមគន្លងខ្សែបញ្ជូនចរន្ត២៣០គ.ម ប្រវែង ១១,០៥ គ.ម ដែលនឹងត្រូវរុះរើ។

មាន៤០គ្រួសារអាចនឹងប៉ះពាល់ដោយសារបង្គោលភ្លើងទាំង ៣៤ បង្គោល។ (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត និងជំពូក៥)។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមការងាររបស់ក្រុមហ៊ុននឹងកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះ ឱ្យបានច្បាស់លាស់រួចដាក់ផ្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។

ការប្រើប្រាស់គ្រឿងផ្ទុះគឺក្រុមហ៊ុននឹងកំណត់កម្រិតរញ្ជួយ និងកំលាំងបំផ្ទុះឱ្យតូចដែលមិនប៉ះពាល់ដល់ការបាក់ផ្នែកខ្លះនៃភ្នំ ឬផ្លូវដែលនៅក្បែរតំបន់បំផ្ទុះ។

ក្រុមហ៊ុននឹងផ្តល់ព័ត៌មាន និងផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះ ដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋដែលរស់នៅទីនោះ។ ជាងនេះទៅទៀត មុនធ្វើការបំផ្ទុះក្រុមហ៊ុននឹងប្រើឧបករណ៍ផ្តល់សញ្ញាជាសំលេងរយៈពេល៥-១០នាទី ជាមុន។

Draft

ក្រុមហ៊ុនជូលដីស្រែ/ចំការ និងដោះស្រាយដំណាំដោយតម្លៃ ៥០០០-១០០០០ ដុល្លារ/ហ. ដែលនៅជាប់នឹងទីតាំងយកថ្មចំងាយ ១០០ ម. ជុំវិញ ដើម្បីការពារការខូចខាត ការគ្រោះថ្នាក់ និងរបួសបណ្តាលមក ពីការបំផ្ទុះថ្មនេះ។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងសងការខូចខាតនៅ ពេលដែលមានការប៉ះពាល់ ក្រៅពីតំបន់ដែលក្រុមហ៊ុនបានជួល។ (មានលម្អិតនៅ ជំពូក៥)

រីឯការប៉ះពាល់ដោយសារខ្សែបញ្ជូនចរន្ត និងបង្គោលភ្លើងវិញ ក្រុមហ៊ុនកំពុងតែបានដោះស្រាយជូនប្រជាពលរដ្ឋ ដោយតម្លៃសមស្របទៅតាមស្ថានភាពជាក់ស្តែងគឺ ៥០០០ USD/ហ.ត ទៅ១០.០០០០ USD/ហ.ត សម្រាប់ដំណាំ និងដី។ (ប្រភពឯកសារៈក្រុមហ៊ុនស៊ីណូហាយត្រូ)។

ការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល (ម៉ោង៤:០០-៥:០០ ល្ងាច)។

ក្រុមហ៊ុនបានសាងសង់ ផ្លូវគ្រួសក្រហម/ល្បាយថ្ម បណ្តោះអាសន្នអមតាមផ្លូវជាតិនេះខាងឆ្វេងដៃ (តាមទិសដៅកំពត-ភ្នំពេញ) ប្រវែង១៣៨៣០មទទឹងខ្នងលើ ៤មហើយភ្ជាប់ពីផ្លូវនេះត្រឹងផ្លូវបត់លោកយាយម៉ៅដល់ការដ្ឋានយកថ្ម ក្រុមហ៊ុនបានស្តារផ្លូវលំចាស់ ប្រវែង ៤៧៥០ម ទទឹងខ្នងលើ ៨ ម ផងដែរ។ សរុបនៃការសាងសង់ផ្លូវចេញ-ចូលរបស់គំរោង នេះមានប្រវែងសរុប ៤១,៧៦ គម. (មានលម្អិតនៅ ជំពូក៥)។

រាល់សំភារៈសំណង់ធន់ធ្ងន់ក្រុមហ៊ុន និងធ្វើការដោះបំបែក និងផ្ទេរចែករំលែកឱ្យងាយក្នុងការដឹកជញ្ជូនវាទោះបីត្រូវប្រើរថយន្តដឹកច្រើនជើងក៏ដោយ ។

ចំពោះអ្នករស់នៅក្រោមខ្សែបញ្ជូនចរន្តទាំង ១៦ ខ្នងផ្ទះ ក្រុមហ៊ុននឹងព្យាយាមបញ្ចៀសឱ្យអស់លទ្ធភាព ដើម្បីកុំឱ្យប៉ះផ្ទះ តែបើសិនជាមិនអាចធ្វើបានក្រុមហ៊ុននឹងជូនសំណងដើម្បីរុះរើផ្ទះដោយតម្លៃសមស្រប។ (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត និងជំពូក៥)

ក្រុមហ៊ុនមានផែនការធ្វើការចរចារដើម្បីទូរទាត់ជាថវិកាជូនប្រជាពលរដ្ឋដែលប៉ះពាល់ទាំងនេះដោយសតិវិធី។

- **ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន**
  - ➢ ហេតុប៉ះពាល់អវិជ្ជមាន

គ្មានលំនៅដ្ឋាន ឬភូមិរបស់ប្រជាពលរដ្ឋនៅក្នុងអាងទី១ និងទំនប់ទី១ឡើយ តែនៅក្បែរទំនប់ទី២ មានភូមិពីរ គឺ ភូមិស្ទឹងប្រាំពីរ (៦២៧គ្រួសារ ត្រូវជា៣០៨៥នាក់ ស្រី៥៦៨នាក់) និងភូមិមាត់៣ម (២៨៧គ្រួសារ ត្រូវជា ១៤៣២នាក់ ស្រី៤៣៦នាក់) នឹងអាចមានការប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគាត់ ព្រោះពួកគាត់មានការភ័យខ្លាចអំពីសុវត្ថិភាពរបស់ខ្លួនមិនហ៊ានចូលព្រៃ ដើម្បីរកអនុផលព្រៃឈើព្រោះខ្លាចការបំផ្ទុះថ្ម និងមានគ្រោះថ្នាក់ដោយថ្មខ្ទាតលើ ឬការផ្តាច់ ផ្លូវចេញចូលដោយការជីកប្រឡាយ ទូនេលការធ្វើផ្លូវចូលជាដើម ។ ជាងនេះទៅទៀត ការដឹកជញ្ជូនសំភារៈ សម្រាប់ដំណើរការសាងសង់ គំរោងដូចជាៈ ទំនប់ អគារថាមពល ការិយាល័យ រោងជាង ផ្ទះស្នាក់នៅរបស់បុគ្គលិកកម្មករ និងការសាងសង់ផ្លូវចេញចូល អាចនឹងធ្វើឱ្យស្ទះចរាចរ និងគ្រោះថ្នាក់ចរាចរដល់ប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវក្បែរតំបន់គំរោង។

ការស្ទាក់ទឹកស្ទឹងកំចាយដើម្បីធ្វើការដ្ឋាននៅផ្នែកខាងលើអាចធ្វើឱ្យបាត់ធារទឹក និងការលាងថ្មដើម្បីធ្វើទំនប់ធ្វើឱ្យមានការបំពុលទឹក ដែលធ្វើឱ្យប៉ះពាល់ដល់រមណីយដ្ឋានទឹកឈូ។

Draft

ប្រជាពលរដ្ឋ នឹងអាចមានការប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគាត់ផងដែរ ព្រោះពួកគាត់មកធ្វើកម្មករឱ្យក្រុមហ៊ុនចិនតែមិនបានទទួលប្រាក់ពលកម្មគ្រប់ចំនួនបើកប្រាក់ឈ្នួលមិនទៀងទាត់ និងមិនបើកប្រាក់ឈ្នួលឱ្យគ្រប់ចំនួនថ្ងៃដែលពួកគាត់បានធ្វើការ ។ ម្យ៉ាងទៀតអាចមានការរើសអើងពូជសាសន៍ ពីព្រោះគំរោងនេះមានមេការជាជនជាតិបរទេស (ជាពិសេសគឺចិន) ហើយគ្មានអ្នកបកប្រែច្បាស់លាស់ដែលធ្វើឱ្យស្តាប់គ្នាមិនបានបង្កជាទំនាស់រវាងកម្មករ ចិន និងខ្មែរអាចសខ្លាចជាបទល្មើសព្រហ្មទណ្ឌទៀតផង ។

ប្រជាពលរដ្ឋអាចនឹងរងការប៉ះពាល់ដល់មុខរបរ និងខាតពេលវេលា រកទទួលទានផងដែរ ដោយសារក្រុមហ៊ុនមិនបានផ្តល់សំភារៈការពារ គ្រោះថ្នាក់ដូចជាៈ មួកការពារ ស្បែកជើង ស្រោមដៃ ខោ អាវ ជាដើម ។ល ។

អាចប៉ះពាល់ដល់ការបង្កបង្កើនផលរបស់ប្រជាពលរដ្ឋមូលដ្ឋាន ព្រោះក្រុមហ៊ុនបានធ្វើបង្គោលភ្លើង និងផ្លូវចូលកាត់តាមស្រែដែលមិនទាន់ប្រមូលផល ។

ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ មានការភ័យខ្លាចអំពីសុវត្ថិភាពរបស់ ខ្លួននៅពេលមានការតវ៉ាអំពីសិទ្ធិរស់នៅ និងកិច្ចសន្យា ដែលបានចែងក្នុងផែនការនៃការតាំងលំនៅដ្ឋានឡើងវិញ ។

ប្រជាពលរដ្ឋនៅក្នុងតំបន់នេះអាចមានការភ័យខ្លាចដោយសារការបាក់រលំបង្គោលបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតពួកគាត់នៅពេលមានព្យុះភ្លៀង ។

នៅខាងក្រោមទំនប់ទី២ មានអ្នកប្រកបរបរចិញ្ចឹមជីវិតនៅតំបន់រមណីដ្ឋានទឹកឈូ ក្នុងពេលសាងសង់គំរោង អាចនឹងធ្វើឱ្យល្អក់ទឹកប៉ះពាល់ដល់ភ្ញៀវទេសចរណ៍ និង មិនមានទឹកសម្រាប់ភ្ញៀវលេង និង ប្រជាពលរដ្ឋរស់តាមមាត់ស្ទឹងកំចាយមានភូមិស្ពំប្រាំពីរ ភូមិមាត់ពាម នៃឃុំម៉ាក់ប្រាំង ភូមិបត់ក្បាលដំរី ភូមិម៉ាក់ប្រាំង ភូមិកំពង់ក្រុង ភូមិកំពង់គ្រែង នៃឃុំកំពង់គ្រែង នឹងអាចរងហេតុប៉ះពាល់ដោយប្រយោល ដោយសាភ័យខ្លាចបាក់ទំនប់វារីអគ្គិសនី ។

**សម្គាល់ៈ** ពេលក្រុមការងារកំពុងចុះសិក្សានៅថ្ងៃទី ១០ មិនា ដល់ ៣១ ធ្នូ ឆ្នាំ ២០១០ ប្រជាជននៅតំបន់នេះបានត្អូញត្អែរអំពីការបាត់បង់ភ្ញៀវទេសចរណ៍ដោយសារមិនមានទឹកសម្រាប់ភ្ញៀវលេង ។

➤ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរភូមិស្ពំប្រាំពីរ និងភូមិមាត់ពាម ដើម្បីផ្សព្វផ្សាយពីផែនការអភិវឌ្ឍ នេះជូនប្រជាពលរដ្ឋក្នុងភូមិនេះបានដឹង និងណែនាំប្រជាពលរដ្ឋអំពីការពារគ្រោះថ្នាក់នានាដែលអាចកើតឡើងជាយថាហេតុ ។

ក្រុមហ៊ុននឹងសាងសង់ទំនប់បង្វៀងទឹកពីការដ្ឋានដើម្បីផ្តល់ទឹកមកផ្នែកខាងក្រោមឱ្យគ្រប់គ្រាន់ ។ ជាងនេះទៅទៀត នៅកន្លែងលាងថ្ម និងលាយបេតុងក្រុមហ៊ុននឹងធ្វើប្រព័ន្ធកាត់បន្ថយភាពល្អក់ដោយជីកប្រឡាយជុំវិញរួចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ទំហំ ១០x១០x៣ម.(បណ្តោយxទទឹងxជំរៅ) បន្ទាប់មកទឹកនេះហូរចូលអាងរងកករទី២ មានទំហំ ១០x១៥x៣ម (បណ្តោយxទទឹងxជំរៅ) ។

ក្រុមហ៊ុននឹងឱ្យអាទិភាពដល់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសអ្នកដែល ប៉ះពាល់ដោយសារគំរោងក្នុងការជ្រើសយកកំលាំងពលកម្ម ដើម្បីធ្វើជាបុគ្គលិក/កម្មករគំរោង ។

ក្រុមហ៊ុនចិននឹងគោរពច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ដោយជួលកម្មករធ្វើការ១ថ្ងៃ ៨ម៉ោង ឬ៤៨ម៉ោង ក្នុងមួយសប្តាហ៍ (មាត្រា ១៣៧ នៃច្បាប់ការងារ)។ បើមានការធ្វើការថ្ងៃសំរាក ឬថ្ងៃបុណ្យក្រុមហ៊ុននឹងមានប្រាក់បន្ថែមជូនកម្មករ (មាត្រា ១៣៩ នៃច្បាប់ការងារ)។

ក្រុមហ៊ុននឹងបើកប្រាក់ឈ្នួលដោយផ្ទាល់ជូនកម្មករជារៀងរាល់ពីរសប្តាហ៍ម្តង។

ក្រុមហ៊ុននឹងសម្រួលចរាចរ និងជូនព័តិមានជាមុននៃការបំផ្ទុះ និងអនុញ្ញាតឱ្យប្រជាជនចេញចូលតំបន់គំរោងជាធម្មតា។

ដើម្បីការពារសុវត្ថិភាពកម្មករក្រុមហ៊ុន នឹងចែកជូនពួកគាត់នូវមួកការពារ ស្បែកជើង ស្រោមដៃ ខោ អាវ ជាដើម ព្រមទាំងត្រួតពិនិត្យមើលពីប្រធានក្រុមក្រែងលោមានកម្មកររូបណាមិនប្រើ។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងមានអ្នកបកប្រែភាសាគ្រប់គ្រាន់នៅការដ្ឋាន ដើម្បីឱ្យការងារមានភាពងាយស្រួលរវាងកម្មករ និងអ្នកគ្រប់គ្រងជនជាតិចិន។

ក្រុមហ៊ុននឹងធ្វើការសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយដោយសន្តិវិធីរាល់នូវរាល់ទំនាស់ដែលអាចកើតឡើងជាមួយកម្មករចិន និងខ្មែរ ។

ក្រុមហ៊ុនមានផែនការធ្វើការងារបង្គោលភ្លើង និងផ្លូវចូលតែវដ្ដូវប្រូតកាត់រួច (រដូវប្រាំង) ព្រោះវាមានការងាយស្រួលទាំងការដឹកជញ្ជូនសំភារៈ និងមិនប៉ះពាល់ដល់ការបង្កបង្កើនផលផងដែរ។

ធ្វើការអប់រំដល់បុគ្គលិក ដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូន (មិនលើសទំងន់នាំឱ្យខូចផ្លូវជាតិ ឬផ្លូវលំរបស់សហគមន៍ ល្បឿនបើកបរមិនឱ្យលើសពី ៣០គ.ម ក្នុង១ម៉ោង នៅក្នុងតំបន់ភូមិ និងទីប្រជុំជន ២០គ.ម ក្នុង១ម៉ោង) និងដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរនានា។

ក្រុមហ៊ុននឹងតំឡើងបង្គោលភ្លើងឱ្យមាំតាមលក្ខណៈបច្ចេកទេសដោយបំពាក់ឧបករណ៍សុវត្ថិភាព ដើម្បីធានាមិនឱ្យរលំនៅពេលមានព្យុះភ្លៀងធម្មតា។

ម្យ៉ាងទៀតកម្ពស់កន្លែងដក់របស់ខ្សែតង់ស្យុងខ្ពស់ពីដីមិនតិចជាង១០ម (បទដ្ឋានរបស់អាជ្ញាធរអគ្គិសនីកម្ពុជាមានតិចជាង៨ម)។

ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីផ្សព្វផ្សាយអំពីគោលបំណង និងគោលការណ៍ផ្តល់សំណងនៃការប៉ះពាល់ដោយសារគំរោងនេះ។

ក្រុមហ៊ុននឹងធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយសាងសង់ទំនប់បណ្តោះអាសន្នព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់។

ក្រុមហ៊ុននឹងធ្វើការគ្រោងរចនាគំរោង ដោយគណនាគ្រឹះសំណង់ និងតួទំនប់ឱ្យបានរឹងមាំតាមលក្ខណៈបច្ចេកទេសជាពិសេសគណនា អាយុនៃសំណង់ធ្វើអំពីបេតុងឱ្យបានយ៉ាងតិច៩០ឆ្នាំក្នុងលក្ខណៈធម្មតា (ប្រសិនបើមិនមាន គ្រោះធម្មជាតិ ឬសង្គ្រាម)។

- **ប្រពៃណី វប្បធម៌ និងសាសនា**
  - ➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះអាចមានការប៉ះពាល់ដល់ជំនឿប្រពៃណី របស់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោង (ភូមិស្ទឹងប្រាំពីរ និងភូមិមាត់ពាម) ដោយសារក្រុមហ៊ុនយកបុគលិក-កម្មកររបស់ខ្លួនរហូតដល់ ២២៣៦នាក់ដែលមកពីតំបន់ឆ្ងាយខុស១គ្នា និងមានសញ្ជាតិខុស១គ្នា។

អាចធ្វើឱ្យមានការប៉ះពាល់ដល់សីលធម៌កម្មករផ្សេងទៀតជាពិសេស ស្ត្រី ដែលបណ្តាលមកពីទំលាប់កម្មករប្រុស១ងូត ទឹកអូរ ឬស្ទឹងស្រាតនៅទីលំហរជាដើម (ជាពិសេសកម្មករបរទេស)។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសិក្សាស្វែងយល់អំពីទំនៀមទំលាប់ប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្បែរតំបន់គំរោង ហើយ ផ្សព្វផ្សាយ និងគោរពទៅតាមប្រពៃណីទំនៀមទំលាប់នេះ ដោយមិនធ្វើការបំពាន និងល្មើសឡើយ។

ក្រុមហ៊ុននឹងធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួនអំពីទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋ ដែលរស់នៅក្បែរ តំបន់គំរោង។

បន្ថែមពីលើនេះទៀត ក្រុមហ៊ុននឹងអប់រំណែនាំដល់បុគ្គលិក-កម្មករ របស់ខ្លួនដែលជាជនជាតិខ្មែរ និងបរទេសមិនឱ្យងូត ទឹកស្រាតនៅតាមដងអូរ ឬស្ទឹងឡើយ និងដាក់ពិន័យបើសិនមិនគោរព។

• **ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះអាច នឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកស្ទឹងដោយសារសកម្មភាពសាងសង់ហេដ្ឋារចនា សម្ព័ន្ធរបស់គំរោង (លម្អិតហេដ្ឋារចនាសម្ព័ន្ធគំរោងមានចែងក្នុងជំពូក៤) និងគ្រប់គ្រងកាកសំណល់រឹង-រាវមិនបានល្អធ្វើឱ្យបំពុល ដល់ប្រភពទឹកលើដី និងក្រោមដីដែលជាប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹកកម្មករក្នុងតំបន់។

បរិមាណធារទឹករបស់ស្ទឹងកំចាយអាចនឹងប៉ះពាល់ដោយសារការទប់ទំនប់កាត់ស្ទឹងកំចាយ ដើម្បីធ្វើអាងតម្កល់ទឹកដែល ជាហេតុបង្កឱ្យ មានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធលំហូរទឹកផ្សេងទៀត ដែលបែកចេញពីស្ទឹងនៅក្រោមទំនប់។ គុណ ភាពទឹកក៏អាចនឹងប៉ះពាល់ផងដែរ ដោយសារសកម្មភាពសាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមាន ការបំពុលជាហេតុបង្កឱ្យកម្មករ និង ប្រជាពលរដ្ឋ ដែលមករកអនុផលព្រៃឈើមិនអាចប្រើទឹកនេះបាន។

កាកសំណល់រឹង-រាវចេញពីកន្លែងរស់នៅផ្ទះបាយ និងបង្គន់អនាម័យ របស់បុគ្គលិក-កម្មករនៃគំរោង ការលេចធ្លាយ ប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់អាចបង្កឱ្យទឹកស្ទឹងកំចាយបាត់បង់គុណភាពដែរ។ ហើយការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់ នៅក្នុង ឬក្បែរស្ទឹងនឹងធ្វើឱ្យគុណភាពទឹកស្ទឹងកំចាយមានការថយ ចុះ និងឈានទៅដល់ការបំពុលទឹក។

➢ **វិធានការណ៍កាត់បន្ថយ**

ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុននឹងមិនធ្វើនៅរដូវវស្សាទេ។

ក្រុមហ៊ុននឹងធ្វើរបាំងការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ហើយសាងសង់បង្គន់អនាម័យ និងបន្ទប់ ទឹកឱ្យបានគ្រប់គ្រាន់ ទៅតាមចំនួនបុគ្គលិក-កម្មករគំរោង (ក្នុងរយៈពេលសាងសង់អាចមានបុគ្គលិក-កម្មករអតិបរមា ឡើងដល់ ២២៣៦នាក់)។

ក្រុមហ៊ុននឹងធ្វើការអប់រំណែនាំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សំរាម (ដោយសសេរ ជាអក្សរខ្មែរ និងចិន) ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅហើយដាក់ ពិន័យដល់បុគ្គលិក-កម្មករណា ដែលមិន ព្រមធ្វើតាមការណែនាំ។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងម៉ឹងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព គឺកន្លែងចាក់សំរាមដែលបានកំណត់ ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងសាងសង់កន្លែងប្រព្រឹត្តកម្ម ឬអាងសិបទិក ដើម្បីសំអាតទឹកកខ្វក់ពីការិយាល័យផ្ទះ បុគ្គលិកដែលស្នាក់នៅពេលដំណើរការ និងថែទាំគំរោងហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះនឹងមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យ លេខ២៧ អនក្រ.បក របស់រាជរដ្ឋាភិបាល ។

ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។

ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គំរោង ។

ក្រុមហ៊ុននឹងពង្រាបដី និងដាំព្រៃឈើឡើងវិញ និងដាំស្មៅតាមកន្លែងចាក់ចោលដីស្អុយឬសំណល់ថ្ម កន្លែងយកដី និងថ្ម ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក ។

- **រមណីយដ្ឋាន/ទីកន្លែងកំសាន្ត**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការស្ទាក់ទឹកស្ទឹងកំចាយដើម្បីធ្វើការដ្ឋាននៅផ្នែកខាងលើអាចធ្វើឱ្យបាត់ធារទឹក និងការលាងថ្មដើម្បីធ្វើទំនប់ធ្វើឱ្យមានការបំពុលទឹក ដែលធ្វើឱ្យប៉ះពាល់ដល់រមណីយដ្ឋានទឹកឈូ នាំឱ្យមានការខាតបង់ដល់របរលក់ដូររបស់ប្រជាពលរដ្ឋនៅរមណីយដ្ឋាន និងកន្លែងកំសាន្តក្នុងតំបន់ទឹកឈូនេះ ។

ការរំខានដល់សកម្មភាពទេសចរណ៍នៅក្នុងតំបន់ទឹកឈូទាំងមូល ដូចជាការរំខាន ដោយសារភាពចង្អៀត នៃចរាចរ ការបំពុលខ្យល់ពីផ្សែង និងធូលី សំលេង និងរំញ័រ ការបំពុលទឹកឈូធ្វើឱ្យកករល្អក់ និងសោភ័ណ្ឌភាពមិនល្អចេញពីសកម្មភាពសាងសង់ ។ ផលប៉ះពាល់នេះនឹងធ្វើឱ្យមានការថយចុះនៃទេសចរជាតិ និងអន្តរជាតិ ។

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសងទំនប់បង្វៀងទឹកពីការដ្ឋានដើម្បីផ្តល់ទឹកមកផ្នែកខាងក្រោមឱ្យគ្រប់គ្រាន់ ។ ជាងនេះទៅទៀត នៅកន្លែងលាងថ្ម និងលាយបេតុងក្រុមហ៊ុននឹង ធ្វើប្រព័ន្ធកាត់បន្ថយភាពល្អក់ដោយជីកប្រឡាយជុំវិញរូចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ទំហំ ១០x១០x៣ម.(បណ្តោយxទទឹងxជំរៅ) បន្ទាប់មកទឹកនេះហូរចូលអាងរងកករទី២ មានទំហំ ១០x១៥x៣ម (បណ្តោយxទទឹងxជំរៅ) ។

ធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្ន និងត្រូវបើកបរដោយល្បឿនយឺតនៅពេលបើកឆ្លងកាត់តំបន់ទឹកឈូនេះ ដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរនានា ។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងសហការជាមួយនគរបាលទេសចរណ៍ និងរដ្ឋអំណាចនៅក្នុងតំបន់ដើម្បីធ្វើអន្តរាគមន៍នៅពេលដែលមានការកកស្ទះចរាចរ ។ ក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូន (មិនលើសទំងន់នាំឱ្យខូចផ្លូវជាតិ ឬផ្លូវលំរបស់សហគមន៍ល្បឿន បើកបរមិន ឱ្យលើសពី៣០គ.ម ក្នុង១ម៉ោង នៅក្នុងតំបន់ភូមិ និងទីប្រជុំជន ២០គ.ម ក្នុង១ម៉ោង) និងដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរនានា ។

រាល់ការដឹកជញ្ជូននឹងមានការគ្រប់គ្រងតាមបទដ្ឋានត្រឹមត្រូវ (ស្តង់ដា) ដោយមានការគ្របត្រឹមត្រូវដើម្បីការពារការកំពប់ ឬធ្លាយ ឬធ្លាក់ សំភារៈដើម្បីការពារគ្រោះថ្នាក់ជាយថាហេតុ។ ហើយការដឹកជញ្ជូននឹងប្រើរថយន្តថ្មីៗ ដែលមានកង់ច្រើន ដើម្បីការពារកុំមានរំញ័រ និងសំលេងខ្លាំង។

- **ផ្លូវគមនាគមន៏**

> ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការដឹកញ្ជូនសំភារៈបរិក្ខារគ្រឿងចក្រចូលទៅទីតាំងគំរោងអាចបង្កឱ្យមានបញ្ហាបីធំៗ រួមមានៈ (១) ការបាក់ស្ពាន (២) ការបែក ឬស្រុតខូចថ្នល់ និង(៣) ការកកស្ទះចរាចរ និងគ្រោះថ្នាក់ចរាចរលើបណ្តាញផ្លូវថ្នល់មួយចំនួនក្នុងក្រុង និងទីប្រជុំជនមុនចូលដល់ការដ្ឋានសាងសង់របស់គំរោង ។

អាចនឹងប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងតំបន់គំរោងនេះ ដោយសារសកម្មភាពសាងសង់គំរោង និងការដឹកញ្ជូនឧបករណ៏-សំភារៈបរិក្ខារអគ្គិសនី ដែលមានទំងន់រាប់តោនចូលទៅទីតាំងគំរោងបណ្តាលឱ្យមានការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវ ដែលមានចំណោទ ឡើងទួល និងផ្លូវកោង។ល។

អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលតំលើងខ្សែភ្លើងកាត់ ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំជនបទ ដោយសារកម្ពស់ខ្សែមិនទាន់ទាញបានដល់ចំណុចកម្ពស់ដែលបានគ្រោង។

អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលតំលើងខ្សែបញ្ជូនចរន្ត ២៣០kV ភ្លើងកាត់ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ ដោយសារកម្ពស់ខ្សែ មិនទាន់ទាញបាន ដល់ចំណុចកម្ពស់ដែលបានគ្រោង ។ (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)

> ➢ **វិធានការណ៏កាត់បន្ថយ**

សាងសង់ផ្លូវម្ខាងទៀតខាងឆ្វេងដៃ នៃព្រែកទឹកឈូមានប្រវែង ៣៨០០ម (មើលផែនទី ១ &៤) ផ្លូវនេះនឹងធ្វើអំពីបេតុងដែកមានទទឹងខ្នងលើ៦ម។ បន្ថែមពីលើនេះ ភ្ជាប់ពីផ្លូវបេតុងនេះមានសាងសង់ផ្លូវលំក្រាលគ្រួសក្រហម/ល្បាយថ្មប្រវែង ១៥៤៣០ម ទទឹងខ្នងលើ ៨ ម ដល់ផ្លូវជាតិលេខ៣ (ក្នុងនោះស្តារផ្លូវចាស់ ប្រវែង ២៦៥០ ម)។ ដើម្បីជៀសវាងការខូចផ្លូវជាតិលេខ៣ដោយសារការដឹកថ្មពីការដ្ឋាន យកថ្មនៅដុបមាន់ព្រៃភូមិទ្វារថ្មី ឃុំព្រៃថ្នង ស្រុកទឹកឈូ ក្រុមហ៊ុនបានសាងសង់ផ្លូវគ្រួសក្រហម/ល្បាយថ្ម បណ្តោះអាសន្នអមតាមផ្លូវ ជាតិនេះខាងឆ្វេងដៃ(តាមទិសដៅកំពត-ភ្នំពេញ) ប្រវែង១៣៨៣០ម. ទទឹងខ្នងលើ ៤ម ហើយភ្ជាប់ពីផ្លូវនេះត្រង់ផ្លូវបត់លោកយាយម៉ៅដល់ការដ្ឋានយកថ្ម ក្រុមហ៊ុនបានស្តារផ្លូវលំចាស់ ប្រវែង ៤៧៥០ម ទទឹងខ្នងលើ ៨ ម ផងដែរ។ សរុបនៃការសាងសង់ផ្លូវ ចេញ-ចូល របស់គំរោងនេះ មានប្រវែងសរុប ៤១,៧៦ គម.។

ក្រុមហ៊ុនសាងសង់ស្ពាន៤កន្លែង ដែលមាន២កន្លែងកាត់ស្ទឹងកំចាយគឺ មួយធ្វើអំពីបេតុងបណ្តោះអាសន្ន (ទល់មុខអគារជាមពលទី១), ស្ពាន បេតុងទី២នៅខាងក្រោមទំនប់ទី១។ ចំណែកឯស្ពានពីរទៀតគឺមួយធ្វើ ពីបេតុងកាត់អូរបី ឬអូរតាជា និងមួយទៀតធ្វើអំពីដែក កាត់ស្ទឹងកែវ ដើម្បីភ្ជាប់ចរាចរផ្លូវសងខាងស្ទឹងទាំងពីរផងដែរ (មើលផែនទី ១ &៤) ។

ធ្វើការកែលំអផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មីទៅកាន់ទីតាំងគំរោង ដែលអាចធានាដល់ការប្រើប្រាស់របស់គំរោង ហើយធ្វើការពិភាក្សាជាមួយស្ថាប័នជំនាញក្នុងការដឹកជញ្ជូនសំភារៈធ្ងន់ៗ។

ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្ន គ្រប់ពេលវេលាហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូនល្បឿនបើកបរមិនឱ្យលើសពី ៣០គ.ម/ម៉ោងនៅក្នុងតំបន់ភូមិ និងទីប្រជុំជនមិនឱ្យលើស២០គ.ម/ម៉ោង) និងដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរនានា ។

ក្រុមហ៊ុននឹងធ្វើការជួសជុលស្ពានដែលមានស្រាប់ដើម្បីធានាលើការដឹកជញ្ជូន និងប្រើប្រាស់ប្រភេទយានយន្តដែល មិនបង្កឱ្យបាក់ស្ពានដែលមានស្រាប់ទាំងនោះ ។

ក្រុមហ៊ុននឹងសហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសម្រួលចរាចរ ក្នុងតំបន់មានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន និងសម្រួលចរាចរនៅពេលដឹកជញ្ជូនគ្រង់ស្ទូរ ។

នៅគ្រប់ចំណុចដែលខ្សែបញ្ជូនចរន្ត ២៣០ kV នេះឆ្លងកាត់ផ្លូវជាតិ ឬផ្លូវរថភ្លើងក្រុមហ៊ុននឹងគ្រោងតំលើងកម្ពស់ខ្សែទាបបំផុតពីដី១៥ម ។ (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត និង ជំពូក៥)

- **សុខភាពសាធារណៈ**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារធូលីដី ធូលីស៊ីម៉ង់ត៍ ចំហាយចេញពីការប្រើប្រាស់សារធាតុគីមីជាដើម ។

អាចប៉ះពាល់ដល់សុខភាពសាធារណៈ (ប្រជាជនក្បែរតំបន់ និងបុគ្គលិក-កម្មករគំរោង) ដោយសារអាចមានការប្រើប្រាស់ ឬចរាចរគ្រឿងញៀន ។

អាចប៉ះពាល់ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មករគំរោង ដោយសារមិនចាប់អារម្មណ៍អំពីសុវត្ថិភាពការងារ ។

ក្នុងតំបន់គំរោងគ្មានប្រព័ន្ធទឹកស្អាតសម្រាប់បរិភោគទេ ដោយសារខ្វះទីផ្សារ (តំបន់នេះជាតំបន់ដាច់ស្រយាល) ។

ការងារសាងសង់របស់គំរោង អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារការធ្វេសប្រហែស និងភាពគ្មានសុវត្ថិភាពក្នុងការងារ ។

ទន្ទឹមគ្នានេះដែរ អាចបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក កម្មកររបស់គំរោង និងប្រជាពលរដ្ឋក្នុងតំបន់នេះដោយសារបុគ្គលិកកម្មកររបស់ក្រុមហ៊ុន អាចកើតជំងឺគ្រុនចាញ់ ជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗ ហើយចំលងដល់អ្នកភូមិតាមរយៈ ភ្នាក់ងារចំលងរោគផ្សេងៗ (មូស រុយ មេរោគ ។ល។) និងដោយការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់ ។ ការសេពគ្រឿងស្រវឹងក៏អាចចាត់ទុកថាជាជំងឺឆ្លងមួយបានដែរ (ការសេពថ្នាំញៀន

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបងក្នុងសកម្មភាពការងារប្រចាំថ្ងៃ ។

ក្រុមហ៊ុននឹងផ្តល់ម៉ាស់ការពារធូលីដី មួកការពារ ស្បែកជើងស្រោមដៃ ដល់បុគ្គលិក កម្មករគំរោង និងធ្វើការស្រោចទឹកលើផ្លូវថ្នល់ដែលខ្លួនប្រើប្រាស់ក្នុងការសាងសង់គំរោងនេះជាប្រចាំ ។

ក្រុមហ៊ុននឹងសាងសង់ជំរុំស្នាក់នៅរបស់បុគលិក-កម្មករគំរោងឱ្យបានសមរម្យ ដោយមានការផ្គត់ផ្គង់ទឹកស្អាតមានបង្គន់អនាម័យបន្ទប់ទឹកគ្រប់គ្រាន់ និងមានកម្មវិធីអប់រំសុវត្ថិភាព ការងារដល់បុគ្គលិក-កម្មកររបស់គំរោង ។

ក្រុមហ៊ុននឹងមានគ្រូពេទ្យដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជុំវិញស្នាក់នៅរបស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខារគ្រប់គ្រាន់ជាប្រចាំសម្រាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គំរោង ហើយមានរថយន្តសង្គ្រោះបន្ទាន់នៅពេលដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ ។

ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក/កម្មកររបស់ខ្លួនក្នុងការទប់ស្កាត់ជំងឺទាំងនោះកុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ។

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ពិសេសទប់ស្កាត់ការជួញដូរចរាចរគ្រឿងញៀន និងមនុស្ស ។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ ។

ការសាងសង់បង្គោល និងខ្សែនាំភ្លើងអនុវត្តន៍តាមបទដ្ឋានបច្ចេកទេស ដែលត្រង់ហើយខ្ពស់ (ឧទា. កម្ពស់ខ្សែទាប បំផុតពីផ្ទៃដី ៨ម និងមិនសង់ចំពីលើលំនៅដ្ឋានប្រជាពលរដ្ឋជាដើម) ដែលធានាបានមិនបង្កគ្រោះថ្នាក់ដល់សុខភាពប្រជាជនក្នុងមូល ដ្ឋាន ។

- **សោភ័ណ្ឌភាព**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោងនេះអាចនឹងមានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់ដោយសារការកាប់ព្រៃឈើអស់ ឬការឈូសឆាយដីស្អុយ ឬសំណល់ថ្ម ទុកជាគំនរតាមដងផ្លូវការបោះចោលការសំណល់រឹង-រាវមិនត្រឹមត្រូវជាដើម ។ល ។

ការហុយធូលី ដោយសារការឈូសឆាយ ការបំផ្ទុះថ្ម ការដុតព្រៃសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ ។

បន្ថែមពីលើនេះទៀត ការសាងសង់កន្លែងស្នាក់នៅរបស់កម្មករគ្មានរបៀប ដោយឃើញមាននៅគ្រប់ទីកន្លែង ។

បិនបាឧការគ្រប់គ្រងកាកសំណល់រឹង-រាវ សំភារៈគ្រឿងបរិក្ខារ និងឧបករណ៍ផ្សេងបានល្អនៅក្នុង និងក្បែរតំបន់គំរោង ។

  - **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានបង្ហាញនៅក្នុងប្លង់រចនាគំរោងលម្អិតឡើយ ។ ម្យ៉ាងវិញទៀត ការសំរាតគឺធ្វើឡើងនៅកន្លែងដែលសាងសង់សំណង់ជាក់ស្តែងប៉ុណ្ណោះ គឺមិនសំអាតទាំងស្រុងនោះ ។ (ចំពោះកន្លែងដែលនឹងត្រូវសាងសង់ទាំងនេះនឹងធ្វើលម្អិតនៅក្នុងដំណាក់កាលគ្រោងលម្អិតរបស់គំរោង) ។

ក្រុមហ៊ុននឹងធ្វើការពង្រាបគំនរដីស្អុយតាមដងផ្លូវឱ្យបានស្មើល្អមានការគ្រប់គ្រងកាកសំណល់រឹងរាវឱ្យបានល្អ ។

ក្រុមហ៊ុននឹងធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុងប្រើប្រាស់សាងសង់គំរោង ។ ម្យ៉ាងទៀតក្រុមហ៊ុននឹងប្រើប្រាស់សារធាតុផ្ទុះដែលមានភាពរំញ័រ និងរញ្ជួយតិច ។

ក្រុមហ៊ុននឹងដើម្បីរក្សាសណ្តាប់ធ្នាប់ និងការរស់នៅស្អាតក្រុមហ៊ុននឹងសាងសង់ផ្ទះសម្រាប់កម្មករបុគ្គលិកដោយមានរបៀបនៅតាមទីកន្លែងសមស្របព្រមទាំងមានបង្គន់អនាម័យគ្រប់គ្រាន់សាងសងអាងសិបទិច ដើម្បីសំអាតទឹកកខ្វក់មានកន្លែងទុកដាក់កាកសំណល់រឹងត្រឹមត្រូវដោយមានអ្នកទទួលខុសត្រូវ ។

រីឯសំភារៈ គ្រឿងបរិក្ខារ និងឧបករណ៍សាងសង់វិញ ក្រុមហ៊ុននឹងមានកន្លែងរក្សាទុកត្រឹមត្រូវ ។

- **ហានិភ័យ** (Risk)

  - ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងមានហានិភ័យ ដោយសារ គ្រោះធម្មជាតិការកើតមានការរញ្ជួយដី បន្ទុះភ្នំភ្លើងនៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីព្យុះទីហ្វុង ឬព្យុះផ្សេងទៀតពីឈូងសមុទ្រថៃ ដែលជាហេតុបង្កឱ្យមានមហន្តរាយធំៗ ដូចជា ការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ដែលកំពុងសាងសង់ ការបាត់បង់ ឬខូចខាតសំភារៈ និងគ្រឿងចក្រសាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋ ក្បែរខាងតំបន់ គំរោង។

អាចនឹងកើតមានការផ្ទុះសំភារៈគ្រឿងផ្ទុះឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គំរោង និងការឆេះព្រៃក្នុងតំបន់គំរោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធ សំខាន់ៗរបស់គំរោង និងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

អាចនឹងកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជាក៏ជាឧបសគ្គដល់ការងារសាងសង់គំរោង ឬសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងក៏សឹងមាន។

  - ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាប្លង់វិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិនឱ្យមានការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនីស្ទឹងកំចាយនេះ។

ក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្របវិនាទីក្នុងការការពារសុវត្ថិភាពចំពោះ គ្រឿងផ្ទុះ ការឆេះព្រៃ និងឆេះប្រេងឥន្ធនៈ ដោយធ្វើការសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គំរោងឱ្យទាន់ពេលវេលា។

ក្រុមហ៊ុននឹងធ្វើការជូនដំណឹងរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោង ដល់ប្រជាពលរដ្ឋទាំងនោះទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យកើតឡើង។

ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីទំនប់បណ្តោះអាសន្ននៅពេលមានបញ្ហាគ្រោះថ្នាក់ដោយចៃដន្យ ដូចជា ការរញ្ជួយដី សង្គ្រាម និងបាតុភូតរុញច្រានមកលើទំនប់ខ្លាំង ។

ក្រុមហ៊ុននឹងរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះសំភារៈនិងថវិកា ដើម្បីធានាការសង្គ្រោះជាបន្ទាន់នូវហេតុការខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់។

### ៧.៣.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance)

[redacted]

#### ក. ធនធានរូបសាស្ត្រ

- **ប្រព័ន្ធជលសាស្ត្រ** (Hydrologycal System)

  - ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលនេះអាចនឹងមានផលប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រនៃស្ទឹងកំចាយ និងខ្សែទឹកខាងក្រោម ដោយសារការបង្ហាំងទឹក ដើម្បីស្តុកទឹកទុកក្នុងអាងទាំពីរឱ្យបានកំលាំងគ្រប់គ្រាន់សម្រាប់អូសទួប៊ីនភ្លើងកំលាំងសរុប ១៩៤.១ មេហាវ៉ាត់

Draft

និងការបញ្ចេញទឹកពីទំនប់ទី១របស់គំរោងមិនគ្រប់គ្រាន់ធ្វើឱ្យប៉ះពាល់ដល់របបទឹករបស់ស្ទឹងកំចាយដែលស្ថិតនៅចន្លោះទំនប់នោះ និងអគារថាមពលទី១ (ចំងាយ ប្រមាណ ២,៣៦ គ.ម បើវាស់តាមផ្លូវទឹក) ។

ការតម្កល់ទឹកក្នុងអាងដែលមានជំរៅជ្រៅ ហើយផ្ទៃទឹកធំធ្វើឱ្យ បង្កើនការជ្រាបទឹកចូលទៅក្នុងដីច្រើន ដែលធ្វើឱ្យកម្ពស់ទឹកក្រោមដីនៅប៉ែកខាងក្រោមអាងកើនឡើងខ្ពស់ជាងស្ថានភាព ដើមរបស់វាអាចនាំឱ្យខូចខាតដល់ដំណាំ ឬរុក្ខជាតិផ្សេងៗ ។

ម្យ៉ាងទៀត អាចនឹងអាចនឹងប្រែប្រួលរបបជលសាស្ត្ររបស់ព្រែកកំចាយដោយសារការបង្ហូរទឹកពីអាងស្តុកទឹកមកខាងក្រោមមិនគ្រប់គ្រាន់ ដែលធ្វើឱ្យកម្រិតប្រៃនៃទឹកព្រែកនេះឡើងខ្ពស់ជាងមុន ហើយអាចប៉ះពាល់ប្រែប្រួលដល់អេកូឡូស៊ីរបស់ព្រែកនោះ ។

➢ **វិធានការណ៍កាត់បន្ថយ**

**ក្រុមហ៊ុននឹងគ្រោងការគ្រប់គ្រងចាត់ចែងបញ្ចេញទឹកទឹកមានដូចតទៅ:**

***តំបន់ទំនប់ទី១:*** នៅខាងក្រោមតំបន់ទំនប់ទី១ មាន២តំបន់ គឺ

**តំបន់១** គឺគិតពី ទំនប់ទី១ ដល់ អគារថាមពលទី១ (PH1) តាមដងស្ទឹង កំចាយមានចំងាយប្រមាណជា ២,៣៦ គ.ម ។ នៅតំបន់នេះក្រុមហ៊ុននឹងធ្វើការបញ្ចេញទឹកពីអាងទី១ ចំនួន ៤.៥៦ ម$^3$/វិន.ឥតដាច់ទាំងប្រាំង និងវស្សាតាមរយៈអគារថាមពលទី៣ នៅជាប់នឹងទំនប់ទី១នេះ ។

**តំបន់២** គិតពី អគារថាមពលទី១ (PH1) តាមដងស្ទឹងកំចាយដល់ទំនប់ ទី២ ចំងាយ ១,៤ គ.ម ដែលទទួលទឹកបន្តពីតំបន់១ ។ ការបញ្ចេញទឹក តាមរយៈទួលប៊ីននៃអគារថាមពល ទី ១ នេះ គឺ ៥៤, ៥ ម$^3$/វិន./ទួរប៊ីន

***តំបន់ទំនប់ទី២:*** នៅខាងក្រោមតំបន់ទំនប់ទី២ គឺ :

**តំបន់៣** គឺគិតពី ទំនប់ទី២: ដល់ចំណុចប្រសព្វគ្នារវាងស្ទឹងកំចាយ និងស្ទឹងកែវ ចំងាយប្រមាណជា ១០ គ.ម (ស្ទឹងនេះជាស្ទឹងមួយធំផងដែរក្នុងតំបន់នេះ ហើយវាមានផ្ទៃរងទឹកភ្លៀងដោយឡែកពីស្ទឹងកំចាយនេះ ចំពោះទិន្នន័យលំហូរនៃស្ទឹងនេះគ្មានការកត់ត្រា ឬបានសិក្សាឱ្យច្បាស់លាស់នោះទេ តាមប្រភពព័ត៌មានពីប្រជាពលរដ្ឋក្នុងតំបន់ស្ទឹងនេះមានទឹកហូរខួបប្រាំង និងវស្សា) ។ ក្រុមហ៊ុននឹងធ្វើការបញ្ចេញទឹកពីអាងទី២ លើសពី ៥៥ ទៅ ១៦០ ម$^3$/វិន ឥតដាច់តាមអគារថាមពលទី២ ។

ក្រុមហ៊ុននឹងសាងសង់គ្រឹះទំនប់បានល្អមានកម្រិតជ្រាបទឹកតិចហើយនឹងមានការសិក្សាស្រាវជ្រាវអំពីលក្ខណៈទឹកក្រោមដី និងលើដីជាប្រចាំ ។

ក្រុមហ៊ុន នឹងធ្វើការប្រតិបត្តិការគំរោងយ៉ាងណាដើម្បីបញ្ចេញទឹកពី អាងស្តុកទឹកឱ្យបានសមស្របទាំងរដូវវស្សា និងរដូវប្រាំងដើម្បីរក្សាប្រព័ន្ធអេកូឡូស៊ី និងរបបជលសាស្ត្រនៅប៉ែកខាងក្រោមអគារថាមពលឱ្យមានលំនឹង ។

ក្រុមហ៊ុននឹងសង់ស្ថានីយ៍ជលសាស្ត្រសម្រាប់សិក្សាអំពីលក្ខណៈរបស់ស្ទឹងនេះ និងព្រែកកំចាយ ដើម្បីតាមដានការបម្រែបម្រួលរបបទឹករបស់វា ។

តែទោះបីជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននឹងបញ្ចេញទឹកមិនឱ្យតិចជាង ០,៣ម$^3$/វិនាទី ឥតដាច់នាខែប្រាំង និងវស្សា ដើម្បីរក្សាជីវសាស្ត្រនៅ ខាងក្រោមទំនប់ទី២ ។



- **គុណភាពទឹកក្រោមដី និង លើដី**
  - ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងអាចនឹងប៉ះពាល់គុណភាពទឹកលើដី ដោយសារការតម្កល់ទឹកក្នុងអាងដើម្បីអូសទួរប៊ីនកំលាំង ១៩៤.១ មេហ្គាវ៉ាត់ ធ្វើឱ្យលិចផ្ទៃដីសរុប ២០១៥,៧ ហ.ត ដែលមានព្រៃឈើ រុក្ខជាតិស្រទាប់ក្រោម ស្អុយរលួយ ហើយក្នុង រុក្ខជាតិទាំងនេះមានសារធាតុសរីរាង្គ និងគីមីផ្សេងៗទៀតជាច្រើន ។

អាចនឹងប៉ះពាល់ដល់ការរលាយអុកស៊ីសែនរបស់ទឹក ដោយសារការស្តុកទឹក ដែលមានជំរៅលើសពី ១៥ ម. ហើយនឹងធ្វើឱ្យទឹកមានក្លិនស្អុយ ។ ម្យ៉ាងទៀត នៅពេលបង្ហូរទឹកមកខាងក្រោមធ្វើឱ្យទឹក នេះមានក្លិនស្អុយដោយទឹកបាត់អុកស៊ីសែននេះ ។

អាចធ្វើឱ្យប៉ះពាល់គុណភាពក្រោមដី ដោយសារការរលាយសារធាតុខនិកក្នុងដីនៅតំបន់អាងដែលមិនធ្លាប់លិចទឹកធ្វើឱ្យកើនឡើងនៃសារធាតុគីមីទឹកក្រោមដីនៅតំបន់នោះ ។

ការជ្រាបទឹកពីអាងស្តុកទឹកទៅក្រោមដីដែលមានក្លិនស្អុយ ដោយសារទឹកមានកម្រិតអុកស៊ីសែនរលាយទាបនឹងធ្វើឱ្យគុណភាពទឹកក្រោមដីថយចុះ ។

បន្ថែមពីលើនេះទៀត អាចនឹងមានការបំពុលទឹកដោយសារការលាងបាតអាង ដោយបង្ហូរល្បាប់ភក់ និងខ្សាច់ចេញពីបាតអាងនៅរដូវវស្សា ដែលបង្កឱ្យមានក្លិនស្អុយ និងធ្វើឱ្យទឹកស្អឹងល្អក់ ដែលប៉ះពាល់ដល់អ្នកប្រើប្រាស់ទឹកខាងក្រោមជាពិសេសប្រជាពលរដ្ឋ សត្វពាហនៈ សត្វស្លាប និងពពួកសត្វព្រៃជុំវិញតំបន់គំរោងនេះ ។

ការស្តុកទឹកធ្វើជាអាងដ៏ធំនេះ នឹងអាចកើតមានរុក្ខជាតិទឹក ដូចជា: ពើក ចក កំប្លោក និងសត្វល្អិតចង្រៃ ដូចជា មូស បាក់តេរី ដែលបង្កឱ្យមានរំហួតខ្លាំង ការបំពុលគុណភាពទឹកអាង និងការចម្លងជំងឺផ្សេងៗ ដែលកើតចេញពីប្រភពទឹកនេះ ។

- ➢ **វិធានការណ៍កាត់បន្ថយ**

មុននឹងតម្កល់ទឹកក្នុងអាងក្រុមហ៊ុននឹងធ្វើការសំអាតផ្ទៃអាងជាមុនសិន ដូចជា: ការកាប់សំអាតព្រៃឈើ ដំណាំរុក្ខជាតិស្រទាប់ក្រោមទាំងនោះចេញ ។ ការកាប់សំអាត់ព្រៃឈើគឺដាក់ដេញថ្លៃជាសាធារណៈ ហើយថវិការដែលបានមកនេះដាក់ជាថវិកាជាតិ ។

ក្រុមហ៊ុនសាងសង់សំណង់បំបែកចរន្តទឹកដែលនៅខាងក្រោមអគារថាមពលទី១ និងទី២ដែលធ្វើឱ្យទឹកខ្វាយឡើង ហើយមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ហើយធ្វើឱ្យទឹកលែងមានក្លិនស្អុយ ។

ក្រុមហ៊ុននឹងធ្វើការសិក្សា និងពិនិត្យតាមដានរំពីគុណភាពទឹកលើដី និងក្រោមដីជាប្រចាំ ។

ក្រុមហ៊ុននឹងធ្វើការលាងអាងនៅរដូវវស្សានៅពេលដែលស្ទឹងកំចាយ មានធាទឹកអតិបរមា ហើយនឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជូនដំណឹងអំពីការលាងនេះមួយសប្តាហ៍មុនពេលលាងអាងនេះ ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ និងសំភារៈ និងអ្នកឯកទេសសម្រាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹករបស់គំរោង ។

ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយក្រសួងធនធានទឹក( ផ្នែកជលសាស្ត្រ) និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារគុណភាពទឹកប្រសិនបើមានការបំពុលធ្ងន់ធ្ងរ ។

### ១. ធនធានជីវសាស្ត្រ

- **ធនធានព្រៃឈើ និងជំរកសត្វព្រៃ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះ អាចនឹងប៉ះពាល់ដល់ធនធានព្រៃឈើ ដែលជាជំរកសត្វព្រៃច្រើនប្រភេទដូចមានចែងក្នុងជំពូក៥ ដោយសារការបិទទ្វាទឹកតម្កល់ទឹកក្នុងអាងទាំងពីររបស់គំរោង ដែលលិចដីព្រៃឈើសរុបប្រមាណ ១.៧៨៨ ហ.ត ។

អាចនឹងប៉ះពាល់ដល់ជំរកសត្វព្រៃ ដោយសារសកម្មភាពរបស់បុគ្គលិក-កម្មករទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ឬដាក់អន្ទាក់សត្វ និងជួញដូរ ចរាចរឈើ និងសត្វព្រៃ ធ្វើឱ្យឈើ និងសត្វព្រៃទាំងនោះថយចុះឈានទៅរកការបាត់បង់ពូជមួយចំនួន ។

អាចនឹងមានការទន្ទ្រានកាន់កាប់ដីនៅក្នុង ឬក្បែរតំបន់គំរោង (ដែលជាតំបន់ការពាររបស់ក្រសួងបរិស្ថាន) ពីសំណាក់បុគ្គលិក-កម្មករ និងជនឆ្លៀតឱកាសនិយមមកពីខាងក្រៅ ធ្វើឱ្យបាត់បង់សម្បត្តិធម្មជាតិនៅតំបន់នោះ ។

អាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គំរោង ដោយសារ បុគ្គលិក-កម្មករគំរោង ។

  - **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងហាមឃាត់ដល់បុគ្គលិកកម្មកររបស់គំរោងមិនឱ្យទន្ទ្រាន កាន់កាប់ដី ឬរុករានព្រៃ និងបំផ្លាញជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ។

ក្រុមហ៊ុននឹងបញ្ជាឱ្យក្រុមការងារតាមផ្នែករបស់ខ្លួនធ្វើការអប់រំ និងហាមឃាត់ដល់បុគ្គលិក-កម្មករតាមផ្នែក ឬ ក្រុមរបស់ខ្លួនមិនឱ្យទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃ្មុំ ដែល អាចបង្ក ការឆេះព្រៃឈើ ។

ក្រុមហ៊ុននឹងដាក់ពិន័យដល់បុគ្គលិកកម្មករណាដែលប្រព្រឹត្តល្មើសនឹងការហាមឃាត់ខាងលើ ។

ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលអាចនឹងកើតឡើងជាយថាហេតុនៅក្នុងតំបន់គំរោងនោះ ក្រុមហ៊ុននឹងធ្វើការសហការជាមួយ ក្រសួងបរិស្ថាន និងក្រុមការងារឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) ដើម្បីដោះស្រាយ ។

ដោយឡែកចំពោះកិច្ចការពារអគ្គិសភ័យ ក្រុមហ៊ុននឹងបំពាក់នូវឧបករណ៍សំភារៈសម្រាប់ពន្លត់អគ្គីភ័យ/ភ្លើងឆេះព្រៃ និង ប្រព័ន្ធឧបករណ៍ដែលឱ្យសញ្ញាពេលមានអគ្គិភ័យកើតមានឡើង ។



Draft

ជាបន្ថែមក្រុមហ៊ុននឹងត្រៀមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារ ឡើងវិញនូវជំរកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជា ការដាំឈើឡើងវិញនៅតំបន់ដែលគ្មានឈើដុះក្បែរនោះដោយធ្វើការជាមួយក្រសួងបរិស្ថាន និងក្រុមការងារឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) ។

ក្រុមហ៊ុននឹងបំពាក់នូវឧបករណ៍សុវត្ថិភាព និងសំភារៈសម្រាប់ពន្លត់អគ្គិភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ស្វ័យប្រវត្តិនៅតំបន់ទាំងនេះសម្រាប់ផ្តល់សញ្ញាដល់អនុស្ថានីយ៏កំពត ដែលជិតបំផុតពេលមានអគ្គិភ័យកើតឡើង ។ ជាងនេះទៅទៀតក្រុមហ៊ុននឹងសំអាតព្រៃតាមគន្លងក្រោមខ្សែចំលង ៣០ម. (១៥ម.សង្ខាងពីអ័ក្ស) ដើម្បីការពារកុំឱ្យផ្ទុះសេដែលបណ្តាលឱ្យមានភ្លើងឆេះ ។ រីឯដំណាំរបស់ប្រជាពលរដ្ឋវិញ គឺមិនអនុញ្ញាតឱ្យដាំប្រភេទណាដែលមានកំពស់លើសពី ៣ម.ឡើយនៅក្រោមខ្សែចំលងចរន្ត ។(តាមខ្សែបញ្ជូនចរន្តប្រវែង១១,០៥គ.ម.មិនមានព្រៃគួរឱ្យកត់សំគាល់ទេ) (មានលម្អិតនៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)

- **ជីវសាស្ត្រ សត្វព្រៃ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការបាត់បង់ជំរកព្រៃមួយចំនួនក្នុងតំបន់អាងស្តុកទឹករបស់វារីអគ្គិសនីនេះនឹងធ្វើឱ្យមានការថយចុះសត្វព្រៃមួយចំនួននៅក្នុងតំបន់គំរោង ។

ការតម្កល់ក្នុងអាង ដែលមានផ្ទៃទឹកដ៏ធំធេងមិនអាចឱ្យសត្វព្រៃមួយ ចំនួនធំឆ្លងកាត់បាន ជាពិសេសការធ្វើចរាចររបស់ត្រីក្នុងការឆ្លងកាត់ទំនប់ពីតំបន់ខាងក្រោមទំនប់ទាំងពីរ ទៅតំបន់ខាងលើទំនប់ ។

ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់ បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និងថែ ទាំគំរោងក៏បណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃក្នុងតំបន់នេះផងដែរ ដូចជាថយចុះចំនួន និងបាត់បង់ពូជសត្វដែល កំពុងការពារដោយក្រុមការងារឧទ្យាន ជាតិព្រះមុនីវង្ស (បូកគោ) នៃក្រសួងបរិស្ថាន ។

ការអនុវត្តនៅតំបន់នេះអាចធ្វើឱ្យមានការហូរចូលជនចំណូលថ្មីមកពីតំបន់ផ្សេងៗដើម្បីទន្ទ្រានកាន់កាប់ដី និងរស់នៅទីនោះធ្វើឱ្យបាត់បង់ធនធានធម្មជាតិដែលជាទីជំរកសម្រាប់បន្តពូជ និងរកចំណីរបស់សត្វក្នុងតំបន់ទាំងនោះ ។

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងត្រៀមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារឡើងវិញនូវជំរកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញ នៅតំបន់ដែលគ្មានឈើដុះក្បែរនោះដោយធ្វើការជាមួយក្រសួងបរិស្ថាន ។

ក្រុមហ៊ុននឹងមានវិធានការដើម្បីជំនួសសំណង់សិល្បៈការសម្រាប់ឱ្យត្រីឆ្លងកាត់ដោយធ្វើអាងត្រី និងសង់ស្ថានីយ៏សម្រាប់បង្កាត់ពូជត្រី ។ ក្រុមហ៊ុននឹងហាមឃាត់ដាច់ខាតដល់បុគ្គលិក/កម្មកររបស់ខ្លួនក្នុងការ ប្រមាញ់សត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ។

ក្រុមហ៊ុននឹងអប់រំ និងដាក់វិន័យដល់បុគ្គលិក/កម្មករគំរោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ ។

ដើម្បីការពារការកាន់កាប់រុករានទន្ទ្រានដីថ្មីដែលជាព្រៃការពារពីជនចំណូលថ្មីទាំងនោះក្រុមហ៊ុននឹងការសហការ ជាមួយអាជ្ញាធរក្រសួងបរិស្ថាន និងស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យដើម្បីទប់ស្កាត់បញ្ហានេះ ។

Draft

- **ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ឆ្លងតាមការចុះសិក្សាផ្ទាល់ ដោយប្រើឧបករណ៍ចាប់ត្រីរបស់ក្រុម ការងារជលផលបានឱ្យដឹងថានៅក្នុងទំនប់មានត្រីសំខាន់ៗ ចំនួន១៥ប្រភេទ និងក្រោមទំនប់មាន១៧ប្រភេទដែលជាត្រីទឹកសាបនៅក្នុងស្ទឹងកំចាយ ហើយក្រុមការងារក៏បានរកឃើញ ពពួកត្រីទឹកភ្លៀវចំនួន២៦ប្រភេទទៀត ដែលរស់ក្នុងព្រែកកំចាយនេះ និងមានប្រភពមកពីតំបន់ឆ្នេរ។ ការបិទទ្វារទឹកដើម្បីគំកល់ទឹកក្នុងអាងអាចប៉ះពាល់ដល់ប្រភេទវារី សត្វងាយរងគ្រោះថ្នាក់មួយចំនួន។ ដោយសារពួកវាមិនអាចឆ្លងកាត់ទំនប់ចុះឡើងបាន។ ក៏ប៉ុន្តែការបង្កើតអាងទឹកដ៏ធំអាចមានការកើនឡើងនៃវារីសត្វផងដែរ ដូចជាសុភាសិតខ្មែរពោលថា ទីណាមានទឹកគឺទីនោះមានត្រី។

ការបង្ហូរទឹកចេញពីអាង (តាមទួរប៊ីន) និងតាមរយៈបំពង់បង្ហូរទឹក ដើម្បីរក្សាជីវសាស្ត្រក្នុងទឹកដែលមានបរិមាណអុកស៊ីសែនរលាយក្នុងទឹកតិច ធ្វើឱ្យប៉ះពាល់ដល់កត្តាជីវសាស្ត្រ ដែលរស់នៅក្នុងទឹក ឬមច្ឆជាតិ។

អាចធ្វើឱ្យប៉ះពាល់ដល់ការចរាចរត្រីពីខាងក្រោមទំបន់ទៅផ្នែកខាងលើទំបន់ (ទាំងទំនប់ទី១ និងទី២) ដែលបណ្តាលឱ្យបាត់បង់ ឬរារាំងការបង្កកំណើតរបស់ត្រី។

អាងស្តុកទឹករបស់គំរោងវារីអគ្គិសនីអាចនឹងកើតមានរុក្ខជាតិទឹក ដូច ជាពើក ចក កំប្លោក និងសត្វល្អិតចង្រៃ ដូចជា មូស បាក់តេរី ដែលបង្កឱ្យខ្វះអុកស៊ីសែនរលាយក្នុងទឹកធ្វើឱ្យវារីសត្វថយចុះ ឬបាត់បង់ ឬកើនឡើងនៃប្រភេទវារីសត្វថ្មីទៀតដែលមិនធ្លាប់មានក្នុងតំបន់។

អាចនឹងមានការបំពុលទឹកដោយសំណល់រាវ-រឹងពីការិយាល័យ ផ្ទះ បុគ្គលិក-កម្មករដែលស្នាក់នៅពីឃ្លាំងស្តុកសំភារះ និងពីរោងជាង។

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាប្លង់គំរោងដោយរួមបញ្ចូលនូវសំណង់ សិល្បៈការសម្រាប់ឱ្យត្រីឆ្លងកាត់បាន បើមានការសិក្សា រកឃើញថាមានប្រភេទត្រីមានប្រយោជន៍ដល់សេដ្ឋកិច្ចជាច្រើនប្រភេទមានបំលាស់ទីក្នុងការបន្តពូជពីខ្សែទឹកខាងក្រោមទៅខ្សែទឹកលើ ឬពីខ្សែទឹកខាងលើមកខ្សែទឹកខាងក្រោមវិញនៃស្ទឹងកំចាយព្រមទាំងមានការស្នើសុំពីរាជរដ្ឋាភិបាល និងអ្នកឯកទេសជលផលជាតិ។

ប៉ុន្តែក្រុមហ៊ុននឹងមានវិធានការដើម្បីជំនួសសំណង់សិល្បៈការសម្រាប់ឱ្យត្រីឆ្លងកាត់ដោយធ្វើអាងត្រី និងសង់ស្ថានីយ៍ចិញ្ចឹមត្រី។ (**សម្គាល់:** ចំពោះតម្លៃ នៃសំណង់សម្រាប់ត្រីឆ្លងកាត់បានមានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ ផងដែរ។

ក្រុមហ៊ុនសាងសង់សំណង់បំបែកចរន្តទឹកដែលនៅខាងក្រោមអគារថាមពលទី១ និងនៅក្រោមអគារថាមពលទី៣នៃទំនប់ទី១ និងអគារថាមពលទី២ នៃទំនប់ទី២ ដែលធ្វើឱ្យទឹកខ្ពាយឡើងហើយមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ និងធ្វើឱ្យទឹកលែងមានក្លិនស្អុយ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ និងសំភារះ និងអ្នកឯកទេសសម្រាប់សំអាតរុក្ខជាតិ ទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹករបស់គំរោងនឹងមានការគ្រប់គ្រង និងថែទាំនូវសំណង់សម្រាប់ឱ្យត្រីធ្វើចរាចរទៅមកឱ្យបានល្អប្រសើរ (ករណីមានសំណល់បែបនេះ)។

Draft

ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តកម្មកាកសំណល់រាវសម្រាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក កម្មករដែលស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគំរោងហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះនឹងមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈដែលមានចែងក្នុងអនុក្រឹត្យលេខ២៧អនក្រ.បករបស់រាជរដ្ឋាភិបាល ។

**គ.ធនធានសេដ្ឋកិច្ចសង្គម**

- **ប្រពៃណី វប្បធម៌ និង សាសនា**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះ អាចនឹងប៉ះពាល់ដល់ ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់ ដូចជាៈ ពួកគាត់មានជំនឿលើអារក្ស អ្នកតា ព្រៃភ្នំដោយបង្កើតជាព្រៃ អ្នកតាភ្នំជាដើម ដោយសារក្រុមហ៊ុននាំយកបុគ្គលិកកម្មករគំរោង មកពីតំបន់ផ្សេងទៀត ឬជនបរទេស ។

  ➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការណែនាអប់រំដល់បុគ្គលិក-កម្មកររបស់គំរោង ឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ព្រៃភ្នំ ស្ថិតនៅជុំវិញទីតាំងគំរោង ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងដាក់វិន័យដល់បុគ្គលិក-កម្មករគំរោងដែលបំពានលើទំនៀមទំលាប់ប្រពៃណីវប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់ ។

- **ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**

  ➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះ អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅតំបន់ផ្នែកខាងក្រោម ដោយសារទឹកក្នុងអាងស្តុកមានគុណភាពមិនល្អ និងមានក្លិនស្អុយមក ពីការរលួយពីរុក្ខជាតិដែលលិចទឹក និងការខ្វះអុកស៊ីសែនរបស់ទឹក ។

ការគ្រប់គ្រងកាកសំណល់រឹង/រាវ ដែលចេញពីការិយាល័យ ផ្ទះ បុគ្គលិក/កម្មករ ឃ្លាំងស្តុកសំភារៈ រោងជាងជាដើម ដែលធ្វើឱ្យខូចដល់ប្រភពទឹកសម្រាប់ផ្គត់ផ្គង់ក្នុងតំបន់ ។

  ➢ **វិធានការណ៍កាត់បន្ថយ**

មុននឹងបំពេញទឹកក្នុងអាង ក្រុមហ៊ុននឹងធ្វើការសំអាតព្រៃឈើ ដំណាំ រុក្ខជាតិស្រទាប់ក្រោមជាមុនសិន ។

ក្រុមហ៊ុនសាងសង់សំណង់បំបែកចរន្តទឹក ដែលនៅខាងក្រោមអគារថាមពលទី១ , ទី២ និងទី៣ ដែលធ្វើឱ្យទឹកខ្ចាយឡើងហើយមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ និងធ្វើឱ្យទឹកលែងមានក្លិនស្អុយ ។

ក្រុមហ៊ុនសាងសង់ប្រព័ន្ធសំអាតទឹក ដើម្បីផ្គត់ផ្គង់ដល់បុគ្គលិក-កម្មករគំរោង ។

ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តកម្មកាកសំណល់រាវសម្រាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក កម្មករ ដែលស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគំរោងហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះនឹងមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧ អនក្រ.បករបស់រាជរដ្ឋាភិបាល ។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងម៉ឹងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព ។



Draft

ដើម្បីកែប្រែតំបន់នោះមានអនាម័យ និងបរិស្ថានល្អនោះក្រុមហ៊ុននឹងធ្វើការសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ សម្រាប់ការងារនេះ ។

- **ផ្លូវគមនាគមន៍**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការដឹកជញ្ជូនសំភារៈ បរិក្ខារ គ្រឿងចក្រចូលទៅទីតាំងគំរោងអាចបង្កឱ្យមានបញ្ហាបីធំៗ រួមមានៈ (១)ការបាក់ស្ពាន (២) ការបែក ឬស្រុតខូចថ្នល់ និង (៣) ការកកស្ទះចរាចរ និងគ្រោះថ្នាក់ចរាចរលើបណ្តាញផ្លូវថ្នល់មួយចំនួនក្នុងក្រុង និងទីប្រជុំជនមុនចូល ដល់ការដ្ឋានសាងសង់របស់គំរោង ។

អាចនឹងប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ក្នុងតំបន់គំរោងនេះ ដោយសារសកម្មភាពសាងសង់គំរោង និងការដឹកញ្ជូនឧបករណ៍-សំភារៈបរិក្ខារអគ្គិសនី ដែលមានទំងន់រាប់តោនចូលទៅទីតាំងគំរោង បណ្តាលឱ្យមានការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវ ដែលមានចំណោទឡើងទូល និងផ្លូវកោង ។ ល ។

អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលតំលើងខ្សែភ្លើងកាត់ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំជនបទ ដោយសារកម្ពស់ខ្សែចំលងមិនទាន់ទាញបានដល់ចំណុចកម្ពស់ដែលបានគ្រោង ។

ហើយម្យ៉ាងវិញទៀត ដំណាក់កាលនេះអាចនឹងបង្កឱ្យប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍របស់ប្រជាពលរដ្ឋក្បែរតំបន់គំរោង ដូចជា ការបិទផ្លូវមិនឱ្យប្រជាពលរដ្ឋចេញចូល ។

ការកកស្ទះធ្វើឱ្យចង្អៀតលើដងផ្លូវ និងបង្កឱ្យមានគ្រោះថ្នាក់ដោយ សារការធ្វើដំណើររបស់ អ្នកទេសចរណ៍ ប្រជាពលរដ្ឋកាន់តែកើនឡើងដោយរួមទាំងចំនួនបុគ្គលិក-កម្មកររបស់គំរោង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់ផ្លូវ ដែលក្រុមហ៊ុនសាងសងសម្រាប់បម្រើឱ្យគំរោងវារីអគ្គិសនីស្ទឹងកំចាយនេះ តែប្រសិនបើក្រុមហ៊ុនចង់បិទផ្លូវណាមួយ ដើម្បីសុវត្ថិភាព ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងក្រុមហ៊ុននឹងផ្លូវវាងជំនួសវិញ ។

ក្រុមហ៊ុននឹងធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំដោះស្រាយចំពោះបញ្ហាផ្លូវដូចជាៈ ដាក់ផ្លាកសញ្ញាចរាចរ តាមដងផ្លូវធ្វើរបាំងការពារត្រង់ផ្លូវកោង និងមានចំណោទជាដើម ។

ក្រុមហ៊ុនមានផែនការថែទាំជួសជុលផ្លូវដើម្បីធានាសុវត្ថិភាព និងសម្រួលចរាចរក្នុងតំបន់គំរោងឱ្យបានល្អប្រសើរ ។

សាងសង់ផ្លូវម្ខាងទៀតខាងឆ្វេងដៃ នៃព្រែកទឹកឈូមានប្រវែង ៣៨០០ម (មើលផែនទី១៤) ផ្លូវនេះនឹងធ្វើអំពីបេតុងដែកមានទទឹងខ្នងលើ៦ម ។ បន្ថែមពីលើនេះ ភ្ជាប់ពីផ្លូវបេតុងនេះមានសាងសង់ផ្លូវលំក្រាលគ្រួសក្រហម/ល្បាយថ្មប្រវែង ១៥៨៣០ម. ទទឹងខ្នងលើ ៨ ម ដល់ផ្លូវជាតិលេខ៣ (ក្នុងនោះស្តារផ្លូវចាស់ ប្រវែង ២៦៥០ ម) ។ ដើម្បីជាងវាងការខូចផ្លូវជាតិលេខ ៣ ដោយសារការដឹកថ្មពីការដ្ឋាន យកថ្មទៅដុបមាត់ព្រៃភូមិទ្វារថ្មី ឃុំព្រៃថ្នង ស្រុកទឹកឈូ ក្រុមហ៊ុនបាន សាងសង់ផ្លូវគ្រួស ក្រហម/ល្បាយថ្ម បណ្តោះអាសន្នអមតាមផ្លូវ ជាតិនេះខាងឆ្វេងដៃ (តាមទិសដៅកំពត-ភ្នំពេញ) ប្រវែង១៣៨៣០ម. ទទឹងខ្នង លើ ៤ ម ហើយភ្ជាប់ពីផ្លូវនេះ ត្រង់ផ្លូវបត់លោកយាយម៉ៅ ដល់ការដ្ឋានយកថ្ម ក្រុមហ៊ុនបានស្តារផ្លូវលំចាស់ ប្រវែង ៤៧៥០ម ទទឹងខ្នងលើ ៨ ម ផងដែរ ។ សរុបនៃការសាងសង់ផ្លូវ ចេញ-ចូលរបស់គំរោងនេះមានប្រវែងសរុប ៤១.៧៦ គម. ។

Draft

ក្រុមហ៊ុនសាងសង់ស្ពាន៤កន្លែង ដែលមាន២កន្លែងកាត់ស្ទឹងកំចាយគឺ មួយធ្វើអំពីបេតុងបណ្តោះអាសន្ន (ទល់មុខអាគារថាមពលទី១), ស្ពាន បេតុងទី២នៅខាងក្រោមទំនប់ទី១។ ចំណែកឯ ស្ពានពីរទៀតគឺមួយធ្វើ ពីបេតុងកាត់អូរបីឬអូរតាដា និងមួយទៀតធ្វើអំពីដែក កាត់ស្ទឹងកែវ ដើម្បីភ្ជាប់ចរាចរផ្លូវសងខាងស្ទឹងទាំងពីរផងដែរ (មើលផែនទី១៤៤)។

ធ្វើការកែលំអផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មីទៅកាន់ទីតាំងគំរោង ដែលអាចធានាដល់ការប្រើប្រាស់របស់គំរោង ហើយធ្វើការពិភាក្សាជាមួយស្ថាប័នជំនាញក្នុងការដឹកជញ្ជូនសំភារៈធ្ងន់ៗ។

ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូនល្បឿនបើកបរមិនឱ្យលើសពី ៣០គ.ម/ម៉ នៅក្នុងតំបន់ភូមិ និងទីប្រជុំជនមិនឱ្យលើស២០គ.ម/ម៉ ទេ) និងដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរនានា។

ក្រុមហ៊ុននឹងធ្វើការជួសជុលស្ពានដែលមានស្រាប់ដើម្បីធានាលើការដឹកជញ្ជូន និងប្រើប្រាស់ប្រភេទយានយន្តដែលមិនបង្កឱ្យបាក់ស្ពានដែលមានស្រាប់ទាំងនោះ។

ក្រុមហ៊ុននឹងសហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសម្រួលចរាចរ ក្នុងតំបន់មានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន និងសម្រួលចរាចរនៅពេលដឹកជញ្ជូនត្រង់ស្វ។

- **សុខភាពសាធារណៈ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

គំរោងវារីអគ្គិសនីនេះជាពិសេសក្នុងអាងអាចកើតមានរុក្ខជាតិទឹក ដូចជា ចក កំប្លោក សារាយ ពើក និងសត្វល្អិតចង្រៃ ដូចជាមូស បាក់តេរី ឬសត្វល្អិត ដែលអាចបង្កជំងឺ និងចម្លងជំងឺទៅសត្វ និងមនុស្សបាន ជាពិសេសជំងឺកើតឡើងពីប្រភពទឹក (Waterborn diseases)។

អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារតំបន់នេះជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្លំ។

ម្យ៉ាងវិញទៀតដំណាក់កាលនេះអាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះដោយសារបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនអាចចម្លងជំងឺផ្សេងៗដល់អ្នកភូមិក្បែរតំបន់គំរោង ដូចជា ជំងឺអេដស៍ ជំងឺកាមរោគ។ល។

រីឯការគ្រប់គ្រងសំណល់រឹង-រាវ មិនបានល្អនៅតំបន់គំរោងការិយាល័យ កន្លែងស្នាក់នៅបុគ្គលិកគំរោងនោះអាចនឹងមានការប៉ះពាល់ដល់សុខភាពសាធារណៈព្រមទាំងបុគ្គលិកគំរោង។

បន្ថែមពីលើនេះទៀត អាចមានគ្រោះថ្នាក់ដល់អាយុជីវិតទេសចរណ៍ ដែលទស្សនានៅតាមគន្លងខ្សែបញ្ជូនចរន្ត ២៣០ kV ដែលងាយរងឥទ្ធិពលដែនអគ្គិសនីភ្លួចអាំងឌុចស្យុងអេឡិកត្រូស្តាទិក និងអេឡិក-ត្រូម៉ាញ៉េទិកនៅពេលភ្លៀង (នៅតាមគន្លងខ្សែ១១,០៥ គ.ម ពីស្ពានទីផលិតថាមពលនៃអគារថាមពលទី១ របស់គំរោងនេះទៅអនុស្ថានីយ៍កំពតខាងក្រោយ សាលាឃុំព្រៃឃ្មុំ ស្រុកទឹកឈូខេត្តកំពត)។

បន្ថែមពីលើនេះទៀត អាចនឹងមានគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋរស់នៅពីក្រោម ឬធ្វើដំណើរកាត់តាមគន្លងខ្សែបញ្ជូនចរន្ត ២៣០kV នេះដោយសារការរងឥទ្ធិពលដែនអគ្គិសនីភ្លួចអាំងឌុចស្យុង អេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញ៉េទិក

Draft

( មានផ្ទះប្រជាជនរស់នៅតាមគន្លងខ្សែ១១.០៥ គ.ម នេះចំនួន ១៦ខ្នងផ្ទះ )។ (ការដោះស្រាយមានលម្អិតនៅជំពូក៥) (ជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការពិនិត្យតាមដានគុណភាពទឹកក្នុងអាង និងក្រៅអាង ឱ្យទៀងទាត់ជាប្រចាំប្រសិនបើគុណភាពទឹកក្នុង ឬក្រៅអាងមានការបំពុល ក្រុមហ៊ុននឹងរិះរកមធ្យោបាយដើម្បីធ្វើការកាត់បន្ថយដោយសហការជាមួយស្ថាប័នពាក់ពន្ធ័។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍-សំភារៈ និងអ្នកឯកទេសសម្រាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃដែលនឹងអាចកើតមាននៅក្នុងអាងស្តុករបស់គំរោង។

ជាងនេះទៅទៀតក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ។

ក្រុមហ៊ុននឹងធ្វើការសហការជាមួយស្ថាប័នសុខាភិបាលដើម្បីទប់ស្កាត់ជំងឺឆ្លង ដែលកើតឡើងជាយថាហេតុ។

អាងប្រព្រឹត្តិកម្មកាកសំណល់រាវសម្រាប់សំអាតទឹកកខ្វក់នឹងត្រូវបានសាងសង់ ដើម្បីសំអាតឱ្យមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភព បំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧ អនក្រ.បករបស់រាជរដ្ឋាភិបាល ។

សាងសង់បង្គោលឱ្យខ្ពស់ដែលធ្វើយ៉ាងណាឱ្យគម្លាតខ្សែដក់មកដីមានប្រវែង ១៥ម.យ៉ាងតិចដើម្បីការពារកុំឱ្យមានគ្រោះថ្នាក់ ដល់ទេសចរណ៍ និងអ្នកដំណើរនានា។

ជាងនេះទៅទៀតក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយជាប្រចាំអំពីគ្រោះ ថ្នាក់ក្នុងន័យអប់រំ និងដាក់ផ្លាកជាអក្សរខ្មែរ អង់គ្លេស និងចិនមិនឱ្យមនុស្សមករស់នៅ ឬលើកបង្គោល ឬឡើងបង្គោលភ្លើង ឬដើមឈើ ដែលដុះក្នុងតំបន់ដែនអគ្គិសនីនេះ។

ក្រុមហ៊ុននឹងសាងសង់បង្គោលឱ្យខ្ពស់ដែលធ្វើយ៉ាងណាឱ្យគម្លាតខ្សែដក់មកដីមានកម្ពស់ ១០ម យ៉ាងតិច និងកន្លែងខ្សែឆ្លងកាត់ផ្លូវ ១៥ ម យ៉ាងតិច នៃគន្លងខ្សែបញ្ជូនចរន្ត ២៣០kV។ (មាននៅជំពូក៨ស្តីពីខ្សែបញ្ជូនចរន្ត)

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយជាប្រចាំ អំពីគ្រោះថ្នាក់ក្នុងន័យអប់រំមិនឱ្យពួកគាត់មករស់នៅក្រោម ឬលើកបង្គោលលោហៈក្នុងចំណីខ្សែ ឬឡើងបង្គោលភ្លើង ឬឡើងដើមឈើដែលដុះក្នុងតំបន់ដែនអគ្គិសនីនេះ។

ក្រុមហ៊ុន នឹងត្រៀដាក់ខ្សែដីការពារវត្ថុចំលងជូនផ្ទះរបស់ប្រជាពលរដ្ឋ បើសិនផ្ទះនោះមិនអាចរំកិលចេញឆ្ងាយពីដែនអគ្គិសនី។

- **សោភ័ណ្ឌភាព**

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅដំណាក់កាលប្រតិបត្តិ និងថែទាំ ការចោលសំរាម និងការបន្ទោបង់ដោយគ្មានសណ្តាប់ធ្នាប់ពីសំណាក់ភ្ញៀវទេសចរណ៍មកកំសាន្ត ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គំរោងធ្វើឱ្យបាត់សោភ័ណ្ឌភាពក្នុងតំបន់ ។

ការសាងសង់បង្គោល និងខ្សែបញ្ជូនចរន្តអគ្គិសនីតង់ស្យុងខ្ពស់នេះ អាចនឹងមានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់ដោយសារការដំឡើងបង្គោលមិនមានការរត់ត្រង់គ្នា ឬកម្ពស់មិនស្មើគ្នាជាដើម ។ល។

ម្យ៉ាងទៀតអាចនឹងបង្កផលប៉ះពាល់ដល់សោភ័ណ្ឌភាពដល់តំបន់ការពារ និងអភិរក្សទាំងនោះដែរ ដោយសារការរៀបចំបង្គោលខ្សែបណ្តាញ ភ្លើងមិនរត់តាមជួរល្អ។

Draft

➢ **វិធានការណ៍កាត់បន្ថយ**

ក្រុមហ៊ុនវារីអគ្គិសនីស៊ឹងកំចាយ នឹងសហការណ៍ជាមួយក្រសួងបរិស្ថាន ព្រមទាំងក្រសួងទេសចរណ៍ និងអាជ្ញាធរក្នុងការគ្រប់គ្រងថែរក្សាអនាម័យ និងបរិស្ថាន ដើម្បីបង្កើតក្រុមការងារប្រមូលសំរាម ព្រមទាំងមានបង្គន់អនាម័យទៀតផង ។

ការសាងសង់បង្គោល និងខ្សែនាំភ្លើងនេះ ក្រុមហ៊ុននឹងជ្រើសយកការតម្រង់ទិស និងកម្ពស់ទៅតាមស្ថានភាពដី (កម្ពស់ចាប់ពី ៣៥-៦៥ម) ឱ្យបានសមស្របដើម្បីបន្ថយការរំខានដល់ការមើលឃើញទេសភាពតាមដងផ្លូវពីសំណាក់ អ្នកធ្វើដំណើរឆ្លងកាត់តំបន់នេះ ។

ក្រុមហ៊ុននឹងធ្វើគន្លងខ្សែនាំអគ្គិសនីឱ្យបានត្រង់ល្អ ដើម្បីមើលទៅរត់ត្រង់ជួរគ្នា ។

- **ហានិភ័យ** (Risk)

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំនេះហានិភ័យនឹងអាចកើត មានដោយសារការធ្វេសប្រហែសផ្នែកសន្តិសុខ និងអំពើភេរវកម្ម ឬសង្គ្រាម ។

រីឯបាតុភូតគ្រោះធម្មជាតិក៏អាចនឹងកើតមានដូចជា: ការរញ្ជួយដី ឬ បន្ទុះភ្នំភ្លើងនៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀតពីឈូងសមុទ្រថៃ ដែលបង្កឱ្យមានមហន្តរាយធំៗដូចជា: ការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ របស់គំរោង ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់ បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង និងក្បែរខាងតំបន់គំរោង

ការកើតមានការរញ្ជួយដី និងការបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃ អនាគត ដោយសារទំងន់ និង សំពាធទឹកក្នុងអាងស្តុកទឹកដែលមានចំណុះ ៧១៨,០០៦៥ លាន ម៉ែត្រគូប (អាងទី១ចំនួន ៧១៨ លាន និងអាងទី២ចំនួន ០,០០៦៥លាន ម៣) ។

ការឆេះព្រៃក្នុងតំបន់គំរោងដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

ការកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជានិង សង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការនិងថែទាំគំរោងជួនកាលសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងទៀតផង ។

➢ **វិធានការណ៍កាត់បន្ថយ**

បញ្ហាហានិភ័យដោយគ្រោះធម្មជាតិ ក្រុមហ៊ុននឹងធ្វើការសិក្សាតាមដានបន្ថែមទៀត នៅក្នុងដំណាក់កាលនេះ លើហេតុការណ៍ប្រែប្រួលលើកត្តាធម្មជាតិ និងអត្តសញ្ញាណនានាដែលអាចឈានទៅដល់ការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនីស៊ឹងកំចាយនេះ ។

រីឯបញ្ហាដែលកើតឡើងពីការធ្វេសប្រហែសផ្នែកសន្តិសុខ ឬភេរវកម្មនោះវិញក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្រប់វិធានទីក្នុងការការពារសន្តិសុខចំពោះ គ្រឿងផ្ទុះនានា អគ្គិភ័យនានា និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័ន មានសមត្ថកិច្ចដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គំរោង ។

ម្យ៉ាងវិញទៀតក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោងដល់ប្រជាពលរដ្ឋដែលរស់ក្នុង និងក្បែរខាងគំរោងនេះទាំងអស់ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលាតាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យបែបនេះកើតឡើង ។

ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីអាងនៅពេលមានបញ្ហាគ្រោះថ្នាក់ដោយ ចៃដន្យដូចជាៈ ការរញ្ជួយដី ឬសង្គ្រាម ។

បន្ថែមពីលើនេះទៀតក្រុមហ៊ុននឹងរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះសំភារៈ និងថវិកាដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍និងមានប្រសិទ្ធិភាព ។

**សំគាល់ៈ** ទាមទារការសិក្សាច្បាស់លាស់ដើម្បីធានាសុវត្ថិភាពនាពេលអនាគត ។

### **៧.៣.៤ ដំណាក់កាលបិទគំរោង** (Project Closure)

ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុននៃប្រទេសចិននេះនឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជាក្រោយពេលដំណើរការបាន ៤០ ឆ្នាំមក ហើយចំពោះការផ្ទេរហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីនេះមាន ចែងលម្អិតនៅក្នុងកិច្ចសន្យា ។ រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគំរោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាសម្រេចខ្លួនឯងហើយសង្ឃឹមថាក្នុងដំណាក់កាលបិទគំរោង របស់ក្រុមហ៊ុនចិននេះពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ ដែលគួរឱ្យកត់សម្គាល់ឡើយ ។ (ចំពោះបទដ្ឋានបច្ចេកទេស និងគុណភាពរបស់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី ដែលនឹងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលវិញ មានចែងលម្អិតក្នុងកិច្ចសន្យានោះហើយ) ។

ការប៉ាន់ប្រមាណ និងកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការណ៍កាត់បន្ថយត្រូវបានដកស្រង់ចេញពីតារាង៦៧ដូចខាងក្រោម :

Draft